# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយ យាន ឡាញ់ ភេទប្រុស អាយុ៤៧ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ "កងកុមារ"

## មានស្រុកកំណើត នៅភូមិស្រើង ឃុំស្រើង ស្រុកសន្ទុក ខេត្តកំពង់ធំ

## សព្វថ្ងៃរស់នៅភូមិបន្ទាយចាស់ ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

## ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣

## សម្ភាសន៍ដោយៈ ឌី ខាំបូលី

## ០១:០៦:២៣

## ៣៧ ទំព័រ

បូលីៈ អញ្ចឹងខ្ញុំសុំថតសំឡេងផងណ៎ាពូណ៎ា?

ឡាញ់ៈ បាទ! ថតទៅ ។

បូលីៈ ថ្ងៃទី២១ ពូ?

ឡាញ់ៈ ២១ ។

បូលីៈ ពូឈ្មោះអីដែរ?

ឡាញ់ៈ ខ្ញុំឈ្មោះ យាន ឡាញ់ ។

បូលីៈ ពូអាយុប៉ុន្មានហើយ?

ឡាញ់ៈ ខ្ញុំសព្វថ្ងៃអាយុ៤៧ឆ្នាំ ។

បូលីៈ បាទ! ពូមានស្រុកកំណើតនៅណាដែរ?

ឡាញ់ៈ ខ្ញុំនៅភូមិស្រើង ឃុំស្រើង ស្រុកសន្ទុក កាលមុនគេដាក់សន្ទុក តែឥឡូវគេដាក់សម្បូរ ។

បូលីៈ ខេត្តកំពង់ធំ?

ឡាញ់ៈ បាទ! ខេត្តកំពង់ធំ ។

បូលីៈ បាទ! ចុះបច្ចុប្បន្ននេះពូនៅណាដែរ?

ឡាញ់ៈ បច្ចុប្បន្នខ្ញុំនៅភូមិបន្ទាយចាស់ ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

បូលីៈ ពូពីតូចមករៀនបានថ្នាក់ទីប៉ុន្មានដែរ?

ឡាញ់ៈ ខ្ញុំរៀននៅសម័យ៣ឆ្នាំ សម័យកសាង ខ្ញុំរៀននៅមណ្ឌលកុមារ ។

បូលីៈ ចុះមុនសម័យ៣ឆ្នាំ?

ឡាញ់ៈ នៅស្រុកៗ នៅតូចអត់បានរៀនទេ ។

បូលីៈ អត់ទាន់បានចូលរៀនទេអញ្ចឹង?

ឡាញ់: បាទ! នៅស្រុកអត់ទាន់បានរៀនទេ ឆ្នាំ៧៦ កាលហ្នឹងគេប្រមូលគ្រួសារកងទ័ពក៏ទៅនៅ ខាងរតនៈគិរី ។

បូលី: បាទ! ចុះពូមុនសម័យ៣ឆ្នាំពូមានបានចូលសាលាទេ?

ឡាញ់: អត់ទេ! អត់មានបានចូលទេ ។

បូលី: ពូកើតឆ្នាំប៉ុន្មានអញ្ចឹង?

ឡាញ់: ខ្ញុំកើតឆ្នាំ១៩៦៦ ។

បូលី: ៦៦?

ឡាញ់: បាទ!

បូលី: ៦៦ រហូតមកដល់៧៥ ១០ឆ្នាំ?

ឡាញ់: បាទ! ស្រុកលើយើងមិនដែលមានសាលាណា មិនបានរៀនដិតដល់ ខាងកំពង់ធំ ខាងលើចេះ មក ខាងចម្ការឯលើនោះ ។

បូលី: សម័យ លន់ នល់ អត់បានរៀនទេ?

ឡាញ់: អត់បានទេ! នៅតូច ។

បូលី: មានសាលារៀនទេ?

ឡាញ់: មានគេរៀន ។

បូលី: ប៉ុន្តែអត់បានរៀន?

ឡាញ់: អត់បានរៀន ។

បូលី: ពូបងប្អូនប៉ុន្មាននាក់ទាំងអស់ពូ?

ឡាញ់: បងប្អូន៤នាក់ ។

បូលី: ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ឡាញ់: សុទ្ធតែប្រុស ។

បូលី: ចុះពូកូនទីប៉ុន្មានហើយ?

ឡាញ់: ខ្ញុំទី៤ ។

បូលី: ពូពៅគេ?

ឡាញ់: បាទ!

បូលី: សព្វថ្ងៃនៅរស់ទាំង៤ទេ ឬក៏យ៉ាងម៉េច?

ឡាញ់: ស្លាប់ ជាមួយពុកដែលសម័យ៧៩ហ្នឹង ស្លាប់ជាមួយពុកមួយ ។

បូលី៖ ដោយសារអី?

ឡាញ់៖ ស្លាប់កាលហ្នឹង ដែលថាវៀតណាមវ៉ៃចូលមក យើងមិនខាងកងទ័ព ហើយកងទ័ពគាត់ស្លាប់ទៅ គេបាញ់ស្លាប់ទៅ ។

បូលី៖ អញ្ចឹងឪពុកពូកងទ័ព?

ឡាញ់៖ បាទ! កងទ័ព ។

បូលី៖ នៅក្នុងកងពលលេខប៉ុន្មានកងទ័ព?

ឡាញ់៖ កងពលធំ កងពល៨០១ ។

បូលី៖ អ៊ូ! ជាមួយតាសារឿនដែរ?

ឡាញ់៖ បាទ! ជាមួយតាសារឿន គាត់នៅខាងសេដ្ឋកិច្ចដឹកជញ្ជូន ។

បូលី៖ នៅកងដឹកជញ្ជូន?

ឡាញ់៖ បាទ! កងដឹកជញ្ជូនលេខ៨០១ ។

បូលី៖ បាទ! ចុះបងប្រុសពូ?

ឡាញ់៖ បងប្រុសខ្ញុំនៅស្រុក កាលគេយកទៅគាត់ហ្នឹងគេឲ្យទៅយកក្របីៗវាត់របួសធ្ងន់ ទម្រាំអត់បានទៅ គេឲ្យនៅស្រុកជាមួយ ។

បូលី៖ បងទីប៉ុន្មាន?

ឡាញ់៖ បងទី១ ។

បូលី៖ ចុះបងទី២?

ឡាញ់៖ បងទី២ ក៏ទៅទាំងអស់គ្នាជាមួយបងទី៣ ទៅនៅយើងរតនៈគិរី ៧៩យើងរត់មកគាត់ធ្វើកងទ័ព គាត់ស្លាប់ជាមួយពុកហ្នឹងបណ្តោយ ។

បូលី៖ អ៊ូ! ចុះបងទី៣ នៅរស់ទេ?

ឡាញ់៖ បងទី៣ គាត់ស្លាប់ដែរ ស្លាប់ឆ្នាំទៅបាត់ទៅហើយ ។

បូលី៖ អ៊ូ! ដោយសារអីទៅ?

ឡាញ់៖ គាត់ពិការកំបុតជើង ដល់អញ្ចឹងទៅជម្ងឺវាអត់ទៀតទាត់ទេ យើងពិការដួនណាប្រកាច់តឹងៗ ស្លាប់ទៅ ។

បូលី៖ ចុះម្តាយពូ?

ឡាញ់៖ ម្តាយខ្ញុំស្លាប់ឆ្នាំទៅមួយ ។ នុ៎ះ! គាត់ទុកដាក់នោះ ។

បូលី៖ ខាងក្រោយនោះ?

ឡាញ់: បាទ! ខាងក្រោយនោះ ។

បូលី: អញ្ចឹងគាត់ទើបតែខូចថ្មីៗហ្នឹងដែរទេ?

ឡាញ់: ទើបតែខូចទេ ។ ខូចពាឆ្នាំហើយ ។

បូលី: បាទ! ភូមិនេះគេហៅភូមិបន្ទាយចាស់ពូ?

ឡាញ់: បាទៗ!

បូលី: ឃុំព្រះប្រលាយ ។ ពូម៉េចបានគេហៅឃុំព្រះប្រលាយអញ្ចឹង ដឹងទេ?

ឡាញ់: ឃុំព្រះប្រលាយ បើនិយាយឲ្យចំទៅ តាំងពីខ្ញុំមកនៅនេះមកគេហៅព្រះប្រលាយៗ រហូតមក មិនដឹងជាប្រវត្តិវាម៉េចផង ។

បូលី: មិនដឹងប្រវត្តិយ៉ាងម៉េច?

ឡាញ់: បាទ! តាំងពីដើមមកមិនដឹងជាយ៉ាងម៉េចផង ។ ព្រោះខ្ញុំ កាលឆ្នាំ១៩៨២-៨៣ ខ្ញុំចុះមកនៅ ខាងនេះ អញ្ចឹងពូតែព្រះប្រលាយៗមក មិនគេប្រវត្តិពីមុនមក យើងអត់ដឹងដែរទេ ។

បូលី: ចុះពូថា សម័យពាឆ្នាំពូនៅសន្ទុកមែន?

ឡាញ់: ខ្ញុំនៅភូមិស្រើយ ស្រុកសន្ទុក ។

បូលី: ហើយពូរៀននៅណាវិញ?

ឡាញ់: អត់ទេ! ឆ្នាំ៧៦ខ្ញុំចេញទៅនៅនោះ នៅរតនៈគិរី ។

បូលី: ៧៦?

ឡាញ់: បាទ! ឆ្នាំ៧៦ទៅបានមួយឆ្នាំ គេឲ្យខ្ញុំចូលរៀននៅមណ្ឌលកុមារ ។

បូលី: អញ្ចឹង! គេមានមណ្ឌលកុមារគេ?

ឡាញ់: បាទ! គេមានមណ្ឌលកុមារគេ កុមារប្រហែលជា៥០-៦០នាក់ដែរ ។

បូលី: អូ! មណ្ឌលហ្នឹងជាមណ្ឌលរបស់កងពល៨០១ ឬក៏របស់ភូមិភាគឦសាន?

ឡាញ់: កងពល៨០១ ។

បូលី: គេមានមណ្ឌលកុមារគេ?

ឡាញ់: មានមណ្ឌលកុមារ ។

បូលី: សម្រាប់តែកូនចៅរបស់កងទ័ពទេ?

ឡាញ់: បាទ! សម្រាប់តែកូនចៅរបស់កងទ័ពទាំងអស់ ។

បូលី: មានប៉ុន្មានសាលា មានប៉ុន្មានអាគារ?

ឡាញ់: ណែនផ្ទះសម្រាប់កុមារហ្នឹងមាន៣ខ្នង មួយខ្នងប្រហែលជា១០ម៉ែត្រហ្នឹងឯងមួយខ្នងៗ ប៉ុនផ្ទះ ប្រក់ស្បូវទេ ហើយនឹងសាលារៀនមួយ ។

បូលី: គេរៀនយ៉ាងម៉េចទៅពូ?

ឡាញ់: គេរៀនអក្សរយើង គេរៀនស្រះយើងរៀនសព្វថ្ងៃនេះ យើងរៀនចប់ស្រះអស់ហើយបាន គេប្រកបព្យញ្ជនៈ គេរៀនចប់អស់ហើយបានគេបង្រៀនយើងព្យាង្គតម្រួតអីអញ្ចឹងមក ខ្ញុំរៀន បានតែ២ឆ្នាំ អត់ទាន់បានបេះផង ។

បូលី: អត់ទាន់បេះផង?

ឡាញ់: បាទ! អត់ទាន់បេះផង ។

បូលី: អានបាន?

ឡាញ់: អានបាន ។

បូលី: អានហើយអញ្ចឹង?

ឡាញ់: អានបាន ប៉ុនយើងបេះសរសេរអត់ទាន់បេះទេ កាលហ្នឹង ។

បូលី: បើអានដាច់?

ឡាញ់: អានដាច់ អានបានអីៗទាំងអស់ឯង ។

បូលី: អ្ហូ! ហើយចុះគ្រូពីណាគេ?

ឡាញ់: គ្រូបែកបាក់គ្នាអស់ហើយ គ្រូកាលហ្នឹងវាមានគ្រូច្រើនដែរ គ្រូប្រុស២នាក់ គ្រូស្រី២នាក់ ហើយមានអ្នកមើលក្មេងម្នាក់ទៀត ។

បូលី: បាទ! អញ្ចឹងដែលទៅហ្នឹង មានឪពុកពូ ម្ដាយពូ ពូហើយនឹងបងប្រុស២នាក់?

ឡាញ់: បាទ!

បូលី: ទាំងអស់៥នាក់?

ឡាញ់: ៥នាក់ ។

បូលី: នៅសល់បងប្រុសមួយឈឺនៅស្រុកនេះ?

ឡាញ់: បាទ! នៅស្រុក ។

បូលី: បងទី១?

ឡាញ់: បាទ! បងទី១ នៅក្របីរាត់ ។

បូលី: ហើយសព្វថ្ងៃគាត់នៅរស់ទេ?

ឡាញ់: នៅហ្នឹងខ្ញុំយកមកនៅខាងក្រោយ ប៉ុនទៅធ្វើការអត់កើតទេ ចាស់ហើយ ។

បូលីៈ ហើយអត់បានរត់ឡើងភ្នំ ឡើងអីទេ?

ឡាញ់ៈ អត់ទេ! អត់បានទេ គាត់នៅផ្ទះ ។

បូលីៈ បាទ! ដល់ពេលវៀតណាមវៃចូល ប៉ុនពូរៀននៅម្ដុំណា សាលារៀនពូ?

ឡាញ់ៈ ខ្ញុំរៀននៅរតនៈគិរី នៅស្រុកវឺនសៃ ។

បូលីៈ អ៊ូ! នៅទីតាំងធំតែម្ដង?

ឡាញ់ៈ បាទ! នៅទីតាំងធំ ទីតាំងកងទ័ព កន្លែងកងពលធំ ។

បូលីៈ ឪពុកពូគាត់ខាងដឹកជញ្ជូន?

ឡាញ់ៈ បាទ! ខាងដឹកជញ្ជូន ។

បូលីៈ គាត់ប្រធាន ឬក៏ធ្វើកូនចៅគេ?

ឡាញ់ៈ ខ្ញុំអត់ទាន់ អត់សូវដឹងគាត់ដែរហ្នឹង មិនដឹងគាត់តួនាទីគាត់ មិនដឹងធ្វើអីផង ប៉ុនតាមការតាមម៉ែអីនិយាយគាត់ថាអាចគាត់មេគេដែរ មេដឹកជញ្ជូនគេឲ្យៗដឹកជញ្ជូនបាយ ដឹកជញ្ជូនអីៗហ្នឹង

បូលីៈ ហើយការរស់របស់ពូនៅវឺនសៃហ្នឹងមានការលំបាក ឬក៏ស្រួលពេលហ្នឹង?

ឡាញ់ៈ ខ្ញុំបើនិយាយឲ្យចំខ្ញុំបើនៅជាមួយពុកដែលទៅបានមួយឆ្នាំម៉ែគាត់នៅផ្សេង ពុកគាត់នៅផ្សេង ខ្ញុំក៏នៅផ្សេងដូចគ្នា អញ្ចឹង! អត់ដឹងយ៉ាងម៉េចដែរ មិនដឹងគេរៀបចំយ៉ាងម៉េចបើម៉ែគេរៀបចំ ផ្ទះឲ្យនៅផ្សេងតែគាត់ខាងមីងៗនោះឯង ហើយបើខ្ញុំគេរៀបឲ្យមកនៅមណ្ឌលនៅស្រុកជាមួយពុកដែរ ប៉ុនពុកមិនដែលសូវបាននៅផ្ទះឃើញតែទៅបាត់មួយថ្ងៃៗទៅធ្វើការ ហើយដល់ខ្ញុំ ខែដល់ទៅរៀនពុកគាត់ជូនខ្ញុំទៅរៀនតែម្ដង ហើយនេះនៅមណ្ឌលជាមួយខ្ញុំដែរ ។

បូលីៈ អ៊ូ! ម្នាក់ហ្នឹងត្រូវជាយ៉ាងម៉េច?

ឡាញ់ៈ អ្នកផ្សេងទេ ប៉ុននៅមណ្ឌលជាមួយខ្ញុំដែរ ។

បូលីៈ នៅ៨០១ហ្នឹងដែរ?

ឡាញ់ៈ បាទ! នៅ៨០១ហ្នឹង ។

បូលីៈ ដែលនៅហ្នឹងយើងដេកហ្នឹង ហូបហ្នឹងឬយ៉ាងម៉េច?

ឡាញ់ៈ ខ្ញុំទៅនៅមណ្ឌលកុមារហូបបាយ ប៉ុនអ្នកខ្លះគេយកបាយទៅ ព្រឹកឡើងគេយកទៅ ព្រឹកថ្ងៃ ល្ងាច ។

បូលីៈ ៣ពេល?

ឡាញ់៖ ៣ពេល ។

បូលី៖ បាយរហូត?

ឡាញ់៖ ដំបូងបាយ ប៉ុនដល់ក្រោយមកវាងបបរៗរហូត ក្រោយមកបបរៗ រហូតដល់យើងរត់នេះ ។

បូលី៖ បាទ! ហើយម្ហូបបានអីទៅ?

ឡាញ់៖ ម្ហូបសាច់ជ្រូក សាច់អីហ្នឹងឯង ដូចយើងធម្មតាហ្នឹងស្ងោរ ។

បូលី៖ បាទ! មានសាច់ជ្រូក មានអីដែរ?

ឡាញ់៖ មានៗសាច់ជ្រូក មានសាច់គោ មួយថ្ងៃៗមិនដែលអត់ទេ មិនដែលអត់អីហូបទេ ។

បូលី៖ គេផ្គត់ផ្គង់កុមារៗបានជិតដល់ដែរ?

ឡាញ់៖ បាទ! គេផ្គត់ផ្គង់ដែរ ប៉ុនមួយឆ្នាំទេគេផ្គត់ផ្គង់ពេញនោះ ប៉ុនក្រោយមួយឆ្នាំទៀតហ្នឹងយើងហូប បបរទេ ហ្នឹងពួកក្មេងៗបានធំបន្តិចឲ្យគ្នាហូបបបរ បើក្មេងៗយើងល្មមៗគេឲ្យហូបបាយព្រឹក ឡើងឲ្យហូបបបរដូចគ្នា ប៉ុនថ្ងៃឡើងឲ្យហូបបាយ ប៉ុនបាយយើងបាយលាយដំឡូងដែរ ពេលខ្លះ! មួយពេលៗ ដំឡូងមីអីទៅ ។

បូលី៖ គេប្រុងយកកុមារទៅធ្វើអីដឹងទេពូ?

ឡាញ់៖ គេឲ្យទៅរៀន ។

បូលី៖ ទៅរៀនសុទ្ធតែម្តង?

ឡាញ់៖ បាទ! ឲ្យទៅរៀន ប៉ុនដល់កុមារវ័យធំហើយបានគេយកទៅធ្វើកងទ័ព វ័យយើងត្រឹមអាយុ ១៥-១៦-១៧-១៨អីហ្នឹងគេបញ្ជូនទៅកងទ័ពហើយ នៅព្រំដែននោះ ។

បូលី៖ ហើយមណ្ឌលហ្នឹងពីណាគេប្រធាន?

ឡាញ់៖ ប្រធានគេ ខ្ញុំដូចអត់ដឹងប្រធានពីណាទេ កាលហ្នឹង ដូចបងយ៉េន មិនដឹងគ្រូសឿនមិនដឹង ចុះ ២-៣នាក់ យើងមិនដឹងពីណាមួយប្រធានយើងមិនដឹង ។

បូលី៖ បាទ! ឈ្មោះយ៉េន ។

ឡាញ់៖ បងយេន គាត់អ្នកថែកុមារហើយបងសឿនគ្រូអីទេ ២,៣,៤,៥នាក់ដែរ ហើយប៉ុនរៀនបាន១ ឆ្នាំគេដូរ! បានរៀនៗចឹងទៅ១ឆ្នាំគេដូរយកទៅបាត់ទៅ បើយើងមិនដឹងដែរយើងនៅក្មេងណាស់កាលនោះ ហើយចង់ទៅរៀន ហើយចេញ ពីរៀនមកដាំដំណាំ ដាំស្ពៃដាំចេកកាលហ្នឹងដាំអីធម្មតា បើដំណាំសំខាន់ជាងគេស្ពៃ ត្រប់ ក្មេងធំៗគិត កាប់ រណ្តៅដាំ ចេក ដាំអំពៅតាមមាត់ទន្លេ ។

បូលីៈ មួយថ្ងៃរៀនប៉ុន្មានម៉ោង?

ឡាញ់ៈ មួយថ្ងៃ កុមារចាប់រៀនពីម៉ោង៧កន្លះ ដល់ម៉ោង១១ដែរ ហើយរៀនម៉ោង១ រៀនដល់ ម៉ោង៤ ។

បូលីៈ ចឹងរៀន១ថ្ងៃពេញតែម្ដង?

ឡាញ់ៈ រៀន១ថ្ងៃពេញ ប៉ុន្តែតាមនែកថ្នាក់ មានថ្នាក់តូច ថ្នាក់ទី១តូចៗចឹងគេព្រឹកទៅ ហើយថ្នាក់ធំៗល្ងាចទៅម៉ោង១ ទៅចូលរៀន ។

បូលីៈ ហើយកុមារធំៗ គេឲ្យទៅដាំចេក?

ឡាញ់ៈ ដាំ! កាប់១ដើមម្នាក់ ១ថ្ងៃឲ្យបានកាប់១ដើម អាដើមយើងប៉ុណ្ណេះឯងរណ្ដៅជម្រៅកន្លះម៉ែត្រហ្នឹង រួចនាំគ្នាទៅគាស់ដើមចេក គល់ចេកទៅនាំគ្នាវែក ។ ហើយល្ងាចឡើងៗ នាំគ្នាស្រោចស្ពែកាប់ទន្រ្ទាំងខេត្តចិញ្រ្ចាំ ។

បូលីៈ ធ្វើដី?

ឡាញ់ ធ្វើដី ។

បូលីៈ មានសែងដីដាក់ស្រែទេ?

ឡាញ់ៈ សែង!

បូលីៈ សែងដែរ!

ឡាញ់ សែងអាដីយើង ដីទន្រ្ទាងខេត្តយើងហ្នឹង ដាក់ដាំណាំហ្នឹងតែម្ដង អាដាក់ស្រែអត់ប្រាប់ទៅទេ ដាក់ដំណាំ នាំគ្នាសែងដីហ្នឹងដាក់ដំណាំយើងហ្នឹង អាដំណាំហ្នឹង គេទៅកន្លែងដាំស្លម្ហូបវិញដដែរ ។

បូលីៈ ចឹងការងារកុមារក្រៅពីរៀនសូត្រមាន ដាំចេក កាប់រណ្ដៅដាំចេក ស្រោចបន្លែ!

ឡាញ់ៈ ស្រោចស្ពែហ្នឹង ។

បូលីៈ ស្រោចស្ពែ ហើយហ្នឹងធ្វើដី!

ឡាញ់ គ្រប់ ហើយហ្នឹងធ្វើដីកុំប៉ុសយើងហ្នឹង ។

បូលីៈ ធ្វើយ៉ាងម៉េចពូ ដឹងទេ អាដីកំប៉ុសយើងហ្នឹង គេធ្វើយ៉ាងម៉េច?

ឡាញ់ៈ ដីកំប៉ុស ឃើញគេធ្វើជង្រុកដីយើងធម្មតានេះណា ដូចចង្រុកចឹងទៅ ឃើញក្មេងទៅកាប់ចឹងទៅ កាប់ត្រាំទឹក ហើយនាំគ្នាស្រោចឲ្យរលួយដីនេះឡើងខ្មៅទៅ ហើយទៅលាយជាមួយអាទឹកយើងស្រោច ស្រោចដំណាំទៅ ។

បូលីៈ ឃើញមានលាយអាចម៍គោមានអី?

ឡាញ់	មានលាយតាអាចម៍គោ ។

បូលីៈ	មានលាយដែរ?

ឡាញ់ៈ	បាទ!

បូលីៈ	ដីដំបូក មានលាយទេ?

ឡាញ់ៈ	ដីដំបូក? អត់ ។

បូលីៈ	អត់មានលាយដីដំបូកទេណា៎?

ឡាញ់ៈ	លាយតែអាចម៍ហើយហ្នឹង ទន្រ្ទានខេត្តហ្នឹងកាប់មកដុំៗ ។

បូលីៈ	ទន្រ្ទានខេត្តហើយហ្នឹង អាចម៍គោ?

ឡាញ់ៈ	បាទ! ឃើញលាយឲ្យខ្មៅទៅរលួយឲ្យអស់ទៅ នាំគ្នាស្រោច ទឹកនោម ។

បូលីៈ	ទឹកនោមមួយទៀត ។

ឡាញ់ៈ	បាទ!

បូលីៈ	ចុះលាមកមនុស្ស?

ឡាញ់ៈ	លាមកមនុស្សមិនដែលឃើញសែងយកទៅដាក់ទេ ។

បូលីៈ	អត់ដែរទេណា៎?

ឡាញ់ៈ	បាទ! អត់មានយកទៅដាក់ ។

បូលីៈ	ខ្ញុំកំពុងចង់ឆ្ងល់ថា អារូបមន្តធ្វើជី កាត់ស្លឹកទន្រ្ទាំងខេត្តហ្នឹងណា៎ ខាងខ្មែរក្រហមរៀន ពីណា?

ឡាញ់ៈ	អត់ដឹងដែរ ឃើញតែដាំដំណាំឃើញមានអ្នកដាំដំណាំផ្សេងណា ដូជគាត់ចាស់ទុំគាត់អ្នក ដាំដំណាំ ចឹងគាត់មកដាំហ្នឹងឲ្យយើងមានអ្នកជួយថែ គាត់មានអ្នក២,៣នាក់គ្នាគាត់មកដាំទី ហ្នឹងដែរ ។ មកដាំឲ្យយើងថែហ្នឹងណា៎ គាត់មិនថែហ្នឹង គាត់ជាអ្នកកម្លាំងជួយ អាហ្នឹង មាន ចាស់ៗ៣ទៅ៤នាក់,៥នាក់អីចឹងទៅ ។

បូលីៈ	ព្រោះថា ដើមឈើស្មៅអីមានច្រើនប្រភេទណាពូ បើហេតុអីបានជាទន្រ្ទានខេត្ត ត្រូវបាន ខ្មែរក្រហមជ្រើសរើសយកធ្វើជាជី? វាអាចមានរស់ជាតិពិសេសអីមួយរបស់ដើម ។

ឡាញ់ៈ	វាឆាប់រលួយ! ឆាប់រលួយជាងគេ ។

បូលីៈ	ទី១វាឆាប់រលួយជាងគេ! មានអីពិសេសទេ ក្រៅពីឆាប់រលួយហ្នឹង?

ឡាញ់ៈ	មានអាជាតិមេនោះច្រើន អាមេស្អីគេវាង អាមេសត្វល្អិតនោះណា៎ ។ សត្វល្អិតនោះ ច្រើន បើសិនយើងដាក់ចិញ្ចឹមត្រីនោះត្រូវណា៎ ជាមួយអាចម៍លាយកើតមេហ្នឹងច្រើន ។

អាហ្នឹង វាមានមេវា អាវាវាងសុទ្ធតែមេ មេតូចៗ បើយើងចិញ្ចឹមត្រី អាហ្នឹងត្រីវាស៊ីកូនៗ ហើយគេជីក(ស្តាប់ពុំបាន)ៗ

បូលីៈ គេមានជីកចឹងផង?

ឡាញ់ៈ បាទ! ក្រពុលៗៗ យើងហូបឡើងលែងកើតទៅក្រពុលៗចឹងៗ

បូលីៈ ពេលដែលវៀតណាមវាយចូលមក ពូចូលធ្វើកងទ័ពណាដែរ?

ឡាញ់ៈ ខ្ញុំនៅទេៗ នៅក្មេងនៅឡើងទេ នៅរៀនរហូត ហើយមកតាមផ្លូវនេះ មកតាមនេះឯង មកតាយើងនេះទៅ ទំនាក់ទំនងវាយធ្លាក់ទៅនោះដូចគ្នា ហើយដល់យើង៧៩រត់ហ្នឹង ដល់ឆ្នាំ៨០ យើងឡើងមកលើភ្នំទាំងអស់ៗ ៨០!គេនៅបង្កើតសាលារៀនដែរ បង្កើតកន្លែងមួយៗហ្នឹង គេបង្កើតហ្នឹងខ្ញុំនៅរៀនរហូតៗ

បូលីៈ ពូនៅរៀនរហូត?

ឡាញ់ៈ បាទ! នៅរៀនរហូតៗ រៀនបាន១ឆ្នាំទៀត!

បូលីៈ បានចូលជាទាហាន?

ឡាញ់ៈ អត់ធ្វើទៀត!

បូលីៈ ពេលណាបានធ្វើ?

ឡាញ់ៈ ខ្ញុំនៅជាមួយម៉ែរហូត មានតែបងធ្វើៗ

បូលីៈ ក្រែងពូថានៅ៦១២?

ឡាញ់ៈ បាទ! ៦១២រហូត ដល់តែយើងឆ្នាំ ដូចជា៨០ប៉ុន្មានទេកាលហ្នឹង កាលខ្ញុំនៅ (ស្តាប់ពុំបាន) ទៅនៅទន្លេល្ពៅ ខ្ញុំឈឺតាមផ្លូវខ្ញុំទៅអត់រួច ខ្ញុំនៅហ្នឹងកងពល៦១២ និង១០០២ នេះបណ្តោយៗ នៅហ្នឹង នៅជាមួយពួកបងហឿននេះ នៅរហូតមកៗ

បូលីៈ ខ្ញុំសួរបកទៅ៧៩តិច! នៅពេលដែលពួកវៀតណាមវាយចូល ពេលហ្នឹងពូថាឪពុករបស់ពូនិងបងប្រុសរបស់ពូស្លាប់មិនចឹង?

ឡាញ់ៈ បាទ!

បូលីៈ ស្លាប់យ៉ាងម៉េច?

ឡាញ់ៈ ស្លាប់គាត់កាលហ្នឹង តាមគេប្រាប់ថាពុកគាត់នែកជីកដំឡូង ដល់តែជីកដំឡូងទៅខាងវៀតណាមហ្នឹងគេឡើងមកឃើញនេះបាត់ បាញ់ស្លាប់ធ្លាក់នៅរណ្តៅអណ្តូង ដល់តែមកប្រាប់បងនៅឯកន្លែងនេះបងគាត់នឹកឃើញថាឪពុកគាត់ស្លាប់ គាត់ទៅ ទៅដាក់មួយទៀតនៅហ្នឹងទាំងអស់គ្នាៗ

បូលី៖ ពេលរត់ហ្នឹងហ៎?

ឡាញ់៖ បាទ! អត់ទេពេល៧៩ដែលយើងខ្ទះបែកបាក់គ្នានៅហ្នឹងណា៎ ឪពុកម៉ែបងនៅក្រោយទេ ខ្ញុំមកតែមួយម៉ែជាមួយបងខ្ញុំទី៣មកនៅ ហើយគាត់មកនៅពុកនៅកូន១នៅនោះ ។ ហើយមកមុនៗជាមួយមីងៗរហូតមក ហើយគាត់កន្លែងវាយក្រោយនេះទេ ។

បូលី៖ មាននេះទេ! មានឆ្លងទន្លេនេះទេ?

ឡាញ់៖ ឆ្លង!

បូលី៖ ទន្លេណា?

ឡាញ់៖ ខ្ញុំឆ្លងទន្លេរឹនសែ! មកខាងកន្លែង មកដល់នេះមកឆ្លងនេះមួយទៀតស្ទឹងត្រែង ។

បូលី៖ ទន្លេមេគង្គ?

ឡាញ់៖ បាទ! តាមហ្នឹងមកនេះ មកយើងនៅខាងនេះមក ខាងឆ្លងយើងថ្ងានេះ មកជាំក្សាន្តមក ភ្នំត្បែង ជាប់ផ្សារនេះមក យើងមកនៅចារកន្លួតនេះ ។ ចារកន្លួតនេះបានទៅទៀត រត់ទៅតាមអន្លង់វែង ទៅនៅថ្មពួក ព្រៃមាន់ បានឡើងឡានថៃដឹកយកទៅដាក់នៅពេទ្យ អំពិល៥ដើម ។

បូលី៖ អំពិល៥ដើម ។ នៅក្នុងស្រុកអី?

ឡាញ់៖ នៅព្រំដែនជាមួយថៃ ទៅហ្នឹងឯង ។

បូលី៖ អំពិល៥ដើមហ្នឹងខ្ញុំឮ តែខ្ញុំមិនដឹងថា អំពិល៥ដើមហ្នឹងស្អីគេ ។

ឡាញ់៖ បាទ!ចេញពីអំពិល៥ដើម បានមកនៅអូរអន្ទក់វិញ គេយកមកនៅអូរអន្ទក់បារាំង ធ្លាក់នេះវិញ ។

បូលី៖ សុំអំពិល៥ដើមសិន! ខ្ញុំចង់ដឹងភូមិសាស្ត្រអំពិល៥ដើមហ្នឹងវានៅម្ដុំណា ។ ចាំជួយចង្អុលខ្ញុំតិចណា៎! មានដែនទី ។

ឡាញ់៖ អំពិល៥ដើមនៅក្នុងព្រៃ ខ្ញុំមិនសូវដឹងទេ នៅព្រំដែន ។

បូលី៖ ពូថាពូរត់មក មកកន្លែងអើថ្មពួកមិនចឹងហ៎?

ឡាញ់៖ បាទ!

បូលី៖ នេះថ្មពួកណាពូណា ។ ថ្មពួកនៅខេត្តបន្ទាយមានជ័យ ។

ឡាញ់៖ បាទ!

បូលី៖ ដល់ពេលយើងវាមក វាចូលឧត្តរមានជ័យហើយ ។

ឡាញ់៖ ថ្មពួកបន្ទាយឆ្មារ ។

បូលីៈ បន្ទាយឆ្មារនៅខាងនេះ បន្ទាយមានជ័យ ព្រះនេតព្រះ ស្វាយចេក អូរជ្រៅ បន្ទាយឆ្មារនេះ ។

ឡាញ់ៈ អាហ្នឹងបកទៅបន្ទាយឆ្មារ ចូលទៅព្រៃមាន់ គេហៅព្រៃមាន់ៗ ព្រោះព្រំដែនថៃហ្នឹង ។

បូលីៈ ហើយបានអំពិល៥ដើម ។

ឡាញ់ៈ ហើយបានថៃដឹកយកទៅអំពិល៥ដើម ។

បូលីៈ បើនិយាយទៅអំពិល៥ដើមវានៅទល់មុខអី ទល់មុខថ្មពួក ឬក៏ស្វាយចេក?

ឡាញ់ៈ នៅមួយជួរខាងមុខអូរអន្លក់ ខាងអូរអន្លក់ខាងបារាំងធ្លាក់នោះ ។

បូលីៈ ខាងនេះសំពៅលូន!

ឡាញ់ៈ គម្រៀងភ្នំព្រឹក្ស ។ បាទ! មួយជួរខាងនោះឯង សង្ស័យខាងនោះឯង ព្រោះកាលនោះខ្ញុំនៅតូចដែរ ខ្ញុំដើរវា! អត់ច្បាស់ហេតុដល់នោះឯងអូរអន្លក់បារាំងធ្លាក់ ដល់អំពិល៥ដើមគេដាក់ក្នុងចម្ការ ដឹងឡូងថៃនៅព្រំដែន ហើយដឹកមកវិញ ។

បូលីៈ ចឹងបែបពូនៅមួយចំហៀងខាងនេះ មួយជិនារខាងលិច ។

ឡាញ់ៈ រួចចេញពីអំពិល៥ដើមមក មកអូរនោង ។

បូលីៈ បាទ!

ឡាញ់ៈ ទៅនៅអូរអន្លក់ គេថាឲ្យទៅខាងអើយស្ទឹទៅខាងម៉ាឡៃ មានបានឡើងទៅដល់ម៉ាឡៃណាមិនដល់ពេជ្រចិន្តាផង ទៅត្រឹមតែអូរអន្លក់ផង ក៏ជាប់មកនៅចម្ការអណ្តូងវិញ ចម្ការចេកចម្ការដូង ។

បូលីៈ ចម្ការចេក ចម្ការអណ្តូង?

ឡាញ់ៈ បាទ!

បូលីៈ នៅម្តុំណាចម្ការចេក ចម្ការអណ្តូង?

ឡាញ់ៈ ចម្ការចេក ចម្ការអណ្តូងនៅភ្នំឆ័ត្រហ្នឹង ។

បូលីៈ ភ្នំឆ័ត្រ! ភ្នំឆ័ត្រនៅខាងថ្មពួក ។

ឡាញ់ៈ នៅម្តុំហ្នឹង! នៅបានប្រហែលជាកន្លះខែ ។

បូលីៈ មកណាវិញ?

ឡាញ់ៈ ទៅទាក់ទងបានកម្លាំងគេឡើងឡានមកវិញ មកចុះយើងនៅ៤០នេះ ។

បូលីៈ ៤០វិញ?

ឡាញ់ៈ បាទ!

បូលីៈ មិនមែនទៅមុំពទេ?

ឡាញ់ៈ អត់ទេ! មកនៅ៨៩យើងវិញ ។

បូលីៈ ពេលណា បានទៅមុំព?

ឡាញ់ៈ មុំពអាហ្នឹងដល់តែ៨១ទេ,៨១,៨២ ។

បូលីៈ ៨១ បានមកមុំព ។ អាននេះមុំព!

ឡាញ់ៈ អាហ្នឹងហើយ! ដល់៨៣ បានមកនៅទន្លេឡោមុំពនេះវិញ ដល់នេះ ខ្ញុំមកនៅ១០០២ ខ្ញុំឈឺទៅអត់រួច អត់ទាន់ស្គាល់អាកន្លែងមុំពហ្នឹងផង អត់បានទៅដល់ផង ដល់ទៅ ១០០២ ដកមកយើងនេះវិញរហូត ។

បូលីៈ មកបាន១០០២ណ៎?

ឡាញ់ៈ បាទ!

បូលីៈ ១០០២ យ៉ាងម៉េចទៅទើតែម្តង?

ឡាញ់ ខ្ញុំឈឺទៅអន្តភាពវិញអត់រួច ខ្ញុំចូលទៅអន្តភាពមួយៗ ។

បូលីៈ មូលហេតុដែលពូចង់មក១០០២ ដោយសារមកអន្តភាពចាស់?

ឡាញ់ៈ បាទ!

បូលីៈ ៨០១?

ឡាញ់ៈ បាទ! ទៅទាំងអស់គ្នាហ្នឹង ប៉ុន្តែខ្ញុំទៅខ្ញុំឈឺទៅមិនកើត ខ្ញុំនៅមន្ទីរនេះទៅ ។

បូលីៈ ពូទៅជាមួយគេដែរ?

ឡាញ់ៈ បាទ!

បូលីៈ ចឹងគេធ្វើដំណើរមកណា?

ឡាញ់ៈ ជាមួយ០៥ ជាមួយ(ស្តាប់ពុំបាន)

បូលីៈ ចឹងហ៎?

ឡាញ់ៈ បាទ!

បូលីៈ ចឹងពូធ្វើដំណើរជាមួយប្រពន្ធតា០៥ដែរ?

ឡាញ់ៈ បាទ! ជាមួយគ្នាហ្នឹង កងពលតែមួយ ។

បូលីៈ យាយណន យាយណេនអីហ្នឹង?

ឡាញ់ៈ បាទ!

បូលីៈ យាយណន គាត់ធ្វើអីកាលហ្នឹង?

ឡាញ់៖ គាត់គ្រាប់គ្រងមីងៗ ។

បូលី៖ យាយណាន គាត់ជាមនុស្សយ៉ាងម៉េចទៅពូ?

ឡាញ់៖ បើមើលឡូចំ ខ្ញុំធ្លាប់នៅជាមួយគាត់បើនយោបាយគឺល្អដែរទេ ឃើញមានស្អីទេ យើងទាំងអស់គ្នានាំគ្នាធ្វើ មិនរើសអើងថាបើតាមចិត្តគាត់មិនរើសអើង សម័យយើងនោះធ្វើយ៉ាងម៉េច យើងធ្វើម៉េច គាត់ធ្វើចឹងដូចគ្នាហ្នឹង ។ ហើយថាបើផ្ទះគេមានកន្លែងគេផ្សេង ផ្ទះយើងផ្សេង ផ្ទះគេយើងអត់ដឹង ប៉ុន្តែបើយើងមកធ្វើ(ស្តាប់ពុំបាន) យើងមកធ្វើទាំងអស់គ្នា ។ ហើយតាមផ្លូវនោះ គេដោះស្រាយតាមសេដ្ឋកិច្ចជូនប្រជាជនហ្នឹង មានតិចតួចអី គាត់នាំគ្នាចែកគ្នាហូប ចែកគ្នាអីទៅតាមផ្លូវ ។

បូលី៖ មានលក់ ដូរអង្ករ ដូរអីចែកគ្នាហូប?

ឡាញ់៖ បាទ! ចែកអង្ករគ្នាហូប ទម្រាំទាក់ទងខាងរដ្ឋបាន ។

បូលី៖ ចឹងពូមកអត់ដល់១០០១ទេ?

ឡាញ់៖ អត់ដល់ផង ។

បូលី៖ ពូមកទើត្រឹម១០០២?

ឡាញ់៖ បាទ! ១០០២ហ្នឹង ។

បូលី៖ ហើយក៏ចូលកងពល ៦១២ហ្នឹងទៅ?

ឡាញ់៖ បាទ! មកនៅរហូតដល់សព្វថ្ងៃ ។

បូលី៖ រហូតដល់សព្វថ្ងៃហ្នឹង ។

ឡាញ់៖ បាទ!

បូលី៖ ចុះកងពលដឹងថា១០០២ ចាប់ពីត្រឹមណា?

ឡាញ់៖ ប៉ុច ព្រិច!

បូលី៖ ពើយ ព្រិច?

ឡាញ់៖ បាទ!

បូលី៖ នៅម្តុំណាទៅពើយ ព្រិច?

ឡាញ់៖ នៅម្តុំហ្នឹង១០០២ តែម្តងៗ ខ្ញុំដឹងតែកន្លែងដើរទេ រឿងចំណុចត្រង់ណាៗ ខ្ញុំអត់សូវដឹងទេៗ ១០០២ៗ!

បូលី៖ ប្រក អានសេស?

ឡាញ់៖ បាទ!

បូលី៖ ប្រកអានសេស អានេះដាំតែ ។ ហើយនេះប្រាសាទព្រះវិហារ!

ឡាញ់៖ ឃើញពើយព្រិចដែរ ។

បូលី៖ ពើយព្រិចគេអត់ដាក់ទេ ព្រោះតូចពេកនោះ ឃើញត្រឹមតែភូមិ ។

ឡាញ់៖ ឃើញ១០០២ណា៎ ចាំ១០០២ ។

បូលី៖ ក្នុងនេះគេអត់ដាក់១០០២ទេ ។ ១០០២ឈ្មោះក្នុងសម៏យខ្មែរក្រហមណា៎ នេះសម័យ ឥលូវគេលែងដាក់ហើយ ។

ឡាញ់៖ ១០០២ មិនមែនសម័យខ្មែរក្រហមណា ។

បូលី៖ ១០០២ សម័យដែលយើងនៅលើភ្នំណា ។

ឡាញ់៖ មិនមែនហ្នឹងទេ! ១០០២,១០០៣យើងហ្នឹងនេះ មិនមែន! យូរណាស់ហើយ ។

បូលី៖ តាំងពីឆ្នាំណាមក?

ឡាញ់៖ តាំងពីយើងទៅនៅពុស្សូរតែ១០០២រហូតមក អាហ្នឹងមិនដឹងគេបង្កើតតាំងពីឆ្នាំណាមក យើងអត់ដឹងដែរ បង្គោលឡាក់គេ១០០២,១០០៣ណា៎ ។

បូលី៖ ហូរគេហៅតាមបង្គោលឡាក់?

ឡាញ់៖ ហៅតាមបង្គោលឡាក់ព្រំដែនតា គេមិនមែនយើងបង្កើតឯណានៅជំនាន់ហ្នឹង តាមខ្ញុំដឹង ណា៎ ពុគេហៅថា១០០២,១០០៣រហូតមក ដល់នោះ៨០៨ពីដើមមក ។

បូលី៖ អ៊ូចឹងបានន័យថាបង្គោលឡាក់ទេ១០០២ហ្នឹង?

ឡាញ់៖ ខ្ញុំសង្ស័យបង្គោលឡាក់ទេ ព្រោះខ្ញុំមានខ្ញុំដឹងក្ដីមកពុតែគេហៅតែប៉ុណ្ណឹងរហូតមក ។

បូលី៖ បានន័យថាប្រហែលអាកន្លែងហ្នឹង១០០២នេះ?

ឡាញ់៖ ពុចាស់ៗគេថាមាន ប៉ុន្តែយើងវាមិនដែលជួប ។

បូលី៖ ប៉ុនយើងវាមិនដឹងថាយ៉ាងម៉េចទេណា៎ ។

ឡាញ់៖ យើងមិនដឹងច្បាស់ថាយើងនៅដែលចងក្រងប្រវត្តិសាស្រ្តគេនោះ ។

បូលី៖ ព្រោះខ្ញុំកំពុងតែឆ្ងល់ដែរ ពាក្យថា១០០១,១០០២,១០០៣ហ្នឹង វាយ៉ាងម៉េចបានគេ ហៅចឹង? បើយើងគិតថាបើវាជាបង្គោលឡាក់ គិតមើលពី១០០១ណា!

ឡាញ់៖ ១០០១, ១០០២, ១០០៣ បានទៅដល់នោះ៨០៨ ។

បូលី៖ មកនេះ ៨០៨នៅនែក ។

ឡាញ់៖ ៨០៨នៅខាងអន្លង់វែង?

បូលី៖ បាទ! ខាងអន្លង់វែងនៅប្រកត្រពាំងតាវ ។

ឡាញ់៖ បាទ! ប្រកណាហ្នឹង។

បូលី៖ ប៉ុនបើ១០០២ ទៅ១០០៣ តាម៉ុកអាប្រលោះបង្គោលឡាក់ក៏វាវែងម៉េះ?

ឡាញ់៖ ដឹង! មិនដឹងយ៉ាងម៉េចដែរ។

បូលី៖ បង្គោលឡាក់នេះតែ២ ទៅ៣គីឡូដែរ។

ឡាញ់៖ បាទ! ខ្ញុំអត់សូវដឹងដែរ។

បូលី៖ អានេះវាជាប់៥០០គីឡូនេះ ឡើង៥០,៦០គីឡូនេះ។

ឡាញ់៖ ប៉ុណ្ណឹងឯង។

បូលី៖ ចឹងវាទាល់តែនេះ ប៉ុន្មាន១០០បង្គោលឡាក់អីនោះ ៥០បង្គោលឡាក់,១០០ហើយអានេះ១០០២។

ឡាញ់៖ ២០០១ទន្លេល្ពៅនោះ។

បូលី៖ វាមិនទាន់ច្បាស់ថាឈ្មោះដោយសារអី?

ឡាញ់៖ បាទ! ឈ្មោះអត់ដឹងដែរ។ ប៉ុន្តែអាដឹង ត្រូតែ១០០២,១០០៣ រហូត។

បូលី៖ ចឹងនៅ៦១២ នេះពួនៅ ពួចូលកងទ័ពនៅ នៅពេលហ្នឹង?

ឡាញ់៖ កាលហ្នឹងនៅទេ។

បូលី៖ នៅឈឺ។

ឡាញ់៖ ឈឺនៅកុមារគេដុត ប្រើមិនប៉ុន្មានទេ។

បូលី៖ ហើយឈឺហ្នឹងមានពេទ្យណាព្យាបាល?

ឡាញ់៖ ពេទ្យមានពេទ្យគេ ច្រើនដែរតា។ ពេទ្យកងទ័ពគេហ្នឹង ខ្ញុំដេកនៅពេទ្យហ្នឹង ខ្ញុំនិយាយ។ ខ្ញុំទៅពេទ្យបណ្តោយឈឺ។

បូលី៖ ពេទ្យអីគេ?

ឡាញ់៖ ពេទ្យរដ្ឋគេហ្នឹង។

បូលី៖ នៅម្តុំណាពេទ្យហ្នឹង?

ឡាញ់៖ ពេទ្យហ្នឹងនៅ១០០២ យើងដាក់កន្លែងចម្ការដំឡូង។

បូលី៖ ក្នុងដីខ្មែរ ឬក៏ដីថៃ?

ឡាញ់៖ នៅក្នុងដីថៃ ចាប់គ្នានៅព្រំដែន។

បូលី៖ អាគារពេទ្យប៉ុណ្ណា?

ឡាញ់ៈ យើង និយាយឲ្យចំនៅអាគារពេទ្យយើងធ្វើតែតាមនៅយូរនៅឆាប់ដែលណា៎ យើងនៅបានមួយឆ្នាំ យើងធ្វើបានមួយឆ្នាំចឹងដែរ ដូចថាអ្នកជំងឺច្រើនចេះយើងអ្នកពួកពេទ្យទាំងអស់នាំគ្នាធ្វើរោង។ ធ្វើរោងអាខ្វះ១០ម៉ែត្រ អាខ្វះ១៥ម៉ែត្រអីចឹងទៅ អាខ្វះ៧ម៉ែត្រ អាខ្វះ៥ ម៉ែត្រអីចឹង ធ្វើមន្ទីរពេទ្យគម្រោងចឹងតា គេ២,៣ចឹងទៅ។ ហើយដល់តែពេលគេចូលអុកឡុងខ្លាំង គេរត់ទៅនោះទៀត គោសាងសង់នោះទៀតទៅវាច្រើនកន្លែងដែរ។ ហើយយើងទីហ្នឹងទៅ គេដឹងថាគេអុកឡុងខ្លាំង ចេញពីហ្នឹងទៅទៀត ចល័ត! ប៉ុននិយាយទៅវា ធំៗដែរណារង១០ម៉ែត្រអីហ្នឹង ចុះអ្នករបួសច្រើននោះ ហើយកាប់ឬស្សីធ្វើគ្រែទៅ។

បូលីៈ អ៊ូធ្វើពីឬស្សីណា៎?

ឡាញ់ៈ ធ្វើពីឬស្សី!

បូលីៈ បាទ!

ឡាញ់ៈ ប្រូតស្រូវប្រក់។

បូលីៈ ចុះដែលពូថារៀននៅភ្នំរៀនយ៉ាងម៉េច រៀននៅឯណា?

ឡាញ់ៈ ខ្ញុំរៀននៅ៨០នេះ!

បូលីៈ មិនមែនរៀននៅ១០០២ទេ!

ឡាញ់ៈ អត់ទេ១០០២ អត់បានរៀនទេ។

បូលីៈ ពេលណា បានមកនៅ៨០ពូ?

ឡាញ់ៈ នៅ៨០ឆ្នាំ និយាយឲ្យចំទៅយើងមកនៅនេះមួយសារហើយ នៅ១០០២នេះ ចុះមកនៅ៥០នេះ បានចុះមកនៅប្រកនេះហើយឡើងទៅវិញ យើងវាយនេះ បានវៀតណាមវាយនេះខ្លាំងទៅ គេវាយនេះយើងនេះទៅ គេវាយយកប្រកយើងបាត់ទៅ យើងរត់ទៅនៅអី ៨០ហ្នឹងបណ្ដោយ។

បូលីៈ ៨០មកនៅខាងអូរគ្រាវវិញ?

ឡាញ់ៈ បាទ! ៨០អូរគ្រាវហ្នឹង ទៅនោះគ្នាបង្កើតសាលារៀន រៀនទៀតទៅ។

បូលីៈ សាលារៀនហ្នឹងប៉ុណ្ណាពូ?

ឡាញ់ៈ សាលារៀនហ្នឹង ៨គុណ៨។

បូលីៈ ៧ គុណហ្នឹង៨ម៉ែត្រ?

ឡាញ់ៈ បាទ! ហើយរៀនបានតែ កងពលហ្នឹងដង។

បូលី៖ បានតែកងពេលយ៉ាងម៉េចទៅ?

ឡាញ់៖ បានតែមួយកែន្ទងកងពេលខ្ញុំនេះកន្លែងហ្នឹង ។

បូលី៖ កងពេល៦១២ហ្នឹង?

ឡាញ់៖ បាទ!

បូលី៖ ម៉េចចឹង?

ឡាញ់៖ អានេះកន្លែងសាលាគេផ្សេង គេមានប៉ុន្តែសាលារៀនដែលខ្ញុំរៀនហ្នឹងណា សាលកងទ័ព នោះ គ្រួសារកងទ័ពនោះក្មេងៗទេណា៎! រៀនបានតែប៉ុណ្ណឹង បើអាសាលាធំគេ អត់បាន ចូលរៀនទេ ។

បូលី៖ សាលាធំគេនៅឯណា?

ឡាញ់៖ នៅ៤០ដែរ ។

បូលី៖ មកពីណាទៅ?

ឡាញ់៖ របស់តាម៉ុក ។

បូលី៖ របស់តាម៉ុក?

ឡាញ់៖ បាទ! កើតគ្រូនាយក គ្រូអីគេត្រឹមត្រូវគេដែរតើ!

បូលី៖ មានសាលា មាននាយកគេត្រឹមត្រូវហ៎ើ?

ឡាញ់៖ បាទ! មានគ្រូ មានអីគេ រៀនដល់ថ្នាក់ទី៦ ទី៧សម័យនោះ វាចឹងពួកនេះណា៎ ។

បូលី៖ ចឹង?

ឡាញ់៖ បាទ!

បូលី៖ ទី៦ ទី៧ ឬត្រឹមទី៥ទេ?

ឡាញ់៖ ថ្នាក់ទី៦ រៀនសម័យយើងអ៎នេះ ចូលខ្លះគេប្រលង ចូលស្រុកថៃជាប់សញ្ញាបត្រ័អីៗ នោះ ធ្វើការងារជាទូច ជាមួយអីហ្នឹង ។ ថ្នាក់ទី៧/៦ ទី៧ទេ ។

បូលី៖ ប៉ុន្តែពូអត់បានទៅរៀនសាលា?

ឡាញ់៖ អត់បានរៀនទេ! ទៅរៀនបាន២ថ្ងៃ ម៉ែអត់ស្រួលក៏អត់បានទៅរៀន ដាច់ឈ្មោះបាត់ អត់បានទៅរៀនរហូតមក ។

បូលី៖ សិស្សនៅសាលាតាម៉ុក ប៉ុន្មានខ្ទង់ទាំងអស់?

ឡាញ់៖ សាលាមើលគ្រប់ថ្នាក់ពីថ្នាក់ទី១ រហូតដល់ទី៦ ។

បូលី៖ ទី១ ដល់ទី៦?

ឡាញ់: ទី៦ហ្នឹងឯង មួយសាលាម្នាក់ៗ ។

បូលី: ចឹងមួយថ្នាក់!

ឡាញ់: មួយថ្នាក់សាលាមួយ ។

បូលី: ក្មេងច្រើនដែរទេ?

ឡាញ់: ក្មេងច្រើនដែរតើ! ច្រើនណាស់ក្មេង មិនមែនក្មេងតិចទេ ។ តែវានៅខ្សែស្ទូ វាចម្រុះ វាចម្រុះគ្រប់គ្រួសារកងទ័ពទៅនៅឯចំណុចដីរុំមួយនៅច្រើនណាស់នៅហ្នឹង ប៉ុន្មានពាន់គ្រួសារមិនកើតទេ ។ ហើយក្មេងច្រើនណាស់ ទៅរៀននៅហ្នឹង ទៅនៅមិនចុះគ្នា ។

បូលី: ក្មេងច្រើន ហើយចុះបើសាលាតិចចឹងអត់ទេ?

ឡាញ់: រៀន! ខ្ញុំវាអត់ដែលបានទៅ នៅតែអាកន្លែងសាលាធំហ្នឹងគេ ទៅម្ដងៗ វាពេលដែលគេរៀនមានកម្មវិធី ទៅលេង រត់លេងរត់អី ទៅលេង បើឲ្យខ្ញុំទៅរៀន មិនដែលបានរៀនហ្នឹងគេទេ ដល់កន្លែងហ្នឹង បើខ្ញុំទៅរៀនទៀត កន្លែងកងទ័ព គេថាកងទ័ពអីតូចមួយ ។

បូលី: សាលាហ្នឹងធ្វើពីឈើ ឬក៏ធ្វើពីថ្ម?

ឡាញ់: ធ្វើអពីឈើ ។ ធ្វើពីឈើ យើងកាប់ស្រឡៅមូល ឈើមូលៗ ធ្វើរោងធំ យើងធ្វើតុ ចងផ្ដៅ វល្លិ៍ផ្ដៅ វល្លិ៍អីហ្នឹង ចងណា៎ ។

បូលី: មានតុទេកាលហ្នឹងយើងណា៎

ឡាញ់: តុយើងកាត់! មានតាតុ គេធ្វើអំពីឫស្សី ។ ឫស្សីហើយក្រង នាំគ្នាក្រង ប៉ុន្តែសាលាធំនោះគេមានដាក់ក្ដារយើងធម្មតា ក្ដារតុរៀបធម្មតានៅតាមថ្នាក់ ។

បូលី: មានក្ដារអីដែរ?

ឡាញ់: ខ្ញុំនេះទៅរៀនតាំងពីនៅនេះ ប៉ុន្តែរៀនបានតែបន្តិចកាលនៅ៥០យើងនោះ៥០ ។ រៀនដែរ ដល់ពេលដែលទៅរៀន ខ្ញុំរបួសបាត់ ។

បូលី: របួសដោយសារអី?

ឡាញ់: ដាក់មីនគោននៅក្រោមនេះ យើងយកគ្រាប់ឲ្យគេមួយភ្លែត ។

បូលី: ផ្ទុះ?

ឡាញ់: ផ្ទុះទៅ របួសក៏បានទៅ រហូតក៏អត់បានទៅរៀនទៅ ។

បូលី: នៅអូរ៥០ មានសាលាដែរ?

ឡាញ់: មាន! អាហ្នឹងសាលតាម៉ុកដែរ?

បូលី: តាម៉ុកដែរ?

ឡាញ់៖ បាទ!

បូលី៖ ៤០ សាលាតាម៉ុកដែរ?

ឡាញ់៖ បាទ!

បូលី៖ អូរគ្រាវសាលាតាម៉ុកដែរ?

ឡាញ់៖ បាទ!

បូលី៖ មានគ្រប់កន្លែងទាំងអស់ចឹង ។

ឡាញ់៖ គ្រប់កន្លែង!

បូលី៖ តែមនុស្សនៅ គឺមានសាលា?

ឡាញ់៖ បាទ! ឲ្យតែមានមនុស្សនៅ គឺមានសាលា ។

បូលី៖ ចុះនៅ៤០ មានប៉ុន្មានថ្នាក់?

ឡាញ់៖ ៦ថ្នាក់ នៅ៤០ ។

បូលី៖ ៦ដែរ?

ឡាញ់៖ បាទ! តាមខ្ញុំដឹង៦ បើក្រុមប្រឹក្សាឃុំដែលនៅឆ្ងាយនេះ អាហ្នឹងគេបើករៀនរហូត ។

បូលី៖ ទី១នេះ?

ឡាញ់៖ អត់ទេនេះ! នៅកូនមេឃុំណា ។

បូលី៖ កូនតាម៉ុន?

ឡាញ់៖ បាទ! កូនតាម៉ុនហ្នឹង អាហ្នឹងនៅរៀនជាប់រហូតអាហ្នឹង ។ រៀនរហូតចប់ថ្នាក់ទី៦ របស់វា ។

បូលី៖ ពូមានសល់សៀវភៅពីដើមមកទេ?

ឡាញ់៖ អត់ទេ! ខ្ញុំមិនដែលទុកទេ ។

បូលី៖ ពូរៀនបានថ្នាក់ទីប៉ុន្មានកាលនៅលើភ្នំ?

ឡាញ់៖ រៀនថ្នាក់ទី២ ។

បូលី៖ ត្រឹមទី២ទេណ៎?

ឡាញ់៖ រៀនបំពេញមួយភ្លែតៗ ។

បូលី៖ មួយថ្ងៃរៀនបានប៉ុន្មានម៉ោង?

ឡាញ់៖ មួយថ្ងៃ បើខ្ញុំទៅរៀន រៀនពេលព្រឹក ពីម៉ោង៧កន្លះ ដល់ម៉ោង១០! ទើប ១១ចេញហើយ ។ ល្ងាចឡើងគេ!

បូលីៈ ដូច វេន!

ឡាញ់ៈ ដូច វេន! សាលាតូចដែរ ។

បូលីៈ ពូរៀនតែពេលព្រឹកទេ?

ឡាញ់ៈ បាទ!

បូលីៈ មួយព្រឹករៀនពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន?

ឡាញ់ៈ ម៉ោង៧ព្រឹក ខ្លះដល់ម៉ោង អីម៉ោង៧ៗ ពីរម៉ោង! ម៉ោង៧ ដល់ម៉ោង៩ចេញ ។ អាហ្នឹង រៀនខាងកង់ទ័ពណា ។

បូលីៈ ត្រឹមតែ ម៉ោង៩ទេ? មិនមែនម៉ោង១២ទេ?

ឡាញ់ៈ បាទ! ត្រឹមតែម៉ោង៩ទេ បើសាលារដ្ឋនោះម៉ោង១១ ។ ម៉ោង១១ មិនដែលឃើញដល់ម៉ោង១២ទេ ។ បើខ្ញុំរៀនតែដើរទេ មិនរៀនជាប់ដូចគេនោះ មានអី ខ្ញុំរៀនផងដើរគេហោមកកងទ័ពគាត់មក ។ ដូនកាលបើនៅផ្ទះ៤ ទៅ១០ថ្ងៃ ក៏ទៅរៀនហ្នឹងគេទៅ ។ មិនគ្រួសារប្រជាជនណា៎ បើយើងគ្រួសារកងទ័ពនោះ បានទៅរៀនហ្នឹងគេចន្លោះៗចឹងណា៎ ។

បូលីៈ ហើយមានសៀវភៅមានប៊ិចអីសរសេរអីទេកាលហ្នឹង?

ឡាញ់ៈ មានអី ។

បូលីៈ រៀនអីទៅចឹង?

ឡាញ់ៈ សៀវភៅគេឲ្យស្អីទេមើល! ដូចជាប៉ុន្មានថ្នាក់ទេ គេឲ្យមួយទៅអានហ្នឹង ។

បូលីៈ តែមួយទេ?

ឡាញ់ៈ សៀវភៅអានមួយថ្នាក់ៗ មួយក្បាលៗហ្នឹងឯង ។

បូលីៈ ចែកគ្នាមើលទៅ?

ឡាញ់ៈ ចែកគ្នាមើលទៅ ។ គេមិននេះ គេមិនឲ្យមើលផង គ្រាន់តែដាក់ក្តារខៀនសរសេរបង្រៀនយើងនោះ ហើយបើរឿងសៀវភៅសរសេរ បើខ្លះគេមានលទ្ធភាពគេមានលុយកាក់ គេទិញពីថៃទៅ ។

បូលីៈ ចឹង?

ឡាញ់ៈ បាទ! គេទិញពីថៃ ។

បូលីៈ សៀវភៅសរសេរ?

ឡាញ់: បាទ! អាហ្នឹងគេមានលក់ខ្លះដែរតើ យើងមានលុយ មានកាក់អីយើងទិញបាន ជួនកាល គេឲ្យមក៤ ទៅ១០ក្បាលទៅ ម៉េចបានគ្រប់គ្នា រាប់សិបនាក់នោះៗ ចឹងបាន អ្នកដែលគេទៅរៀន ខាងគេបានទៅ យើងខ្សោយជាងគេក៏អត់ទៅ យើងមានតែក្ដា សរសេរហ្នឹងៗ

បូលី: អូរមានក្ដាឈ្នួននែក?

ឡាញ់: បាទ! ក្ដាឈ្នួនហ្នឹងៗ សរសេរតែក្ដាឈ្នួនហ្នឹងទៅ!

បូលី: ក្ដាឈ្នួន មានគ្រប់ដៃទេ?

ឡាញ់: មានគ្រប់ដៃបាទ! ក្ដាឈ្នួននោះ មិនមែនក្ដាឈ្នួនគេវាយពុម្ពទេ អាក្ដាយើងដែរនៅនោះ ទៅរៀនអាសែងនោះ នាំគ្នាពុះជា២ទៅស្មើដូចក្ដាចាស់ហ្នឹង ដូចតែក្ដាយើងធម្មតា ហ្នឹងៗ នាំគ្នាសរសេរទៅ! ដីស គ្រូចែកឲ្យ មួយដើម២នាក់អីចឹងទៅៗ

បូលី: ចឹងក្ដាឈ្នួននោះ យើងរកខ្លួនឯងទេ?

ឡាញ់: រកខ្លួនយើងៗ

បូលី: មិនមែនសាលាចែកឲ្យទេ?

ឡាញ់: បានតែដីសខ្លះ ១ដើម២ ទៅ៣នាក់អី សន្សំសំចៃៗ អ្នកខ្លះគេមានលទ្ធភាព គេមាន លុយទិញទៅ ក៏ទិញទៅមកពីថៃបានៗ

បូលី: ពីឈើអីគេ?

ឡាញ់: ប្រដាប់ឆ្កែស្រែងៗ

បូលី: ឆ្កែស្រែង?

ឡាញ់: បាទ!

បូលី: ហ៊ូ! ដើមឆ្កែស្រែងធំហ៉ពូ?

ឡាញ់: ធំ! ប៉ុណ្ណេះក៏មាន ប៉ុណ្ណាក៏មានដែរ ឆ្កែស្រែងហ្នឹងៗ

បូលី: អាហ្នឹង ដែលប្ញសគេយក?

ឡាញ់: បាទ!

បូលី: ព្រោះដើមអាហ្នឹងគេយកធ្វើក្ដាៗ

ឡាញ់: អាហ្នឹងស៊ីទៀត អាហ្នឹងគេហូបទៀត?

បូលី: អត់ទេ!

ឡាញ់: ប្ញស ដូចគេធ្វើថ្នាំ!

បូលីៈ ខ្ញុំចាប់អារម្មណ៍កន្លែងតួរៀនលើភ្នំហ្នឹងណា៎! ចាប់អារម្មណ៍កន្លែងសាលារៀនណាពូ ព្រោះអាហ្នឹងឆ្លុះបញ្ចាំងពីការរៀនសូត្ររបស់យើងនៅលើភ្នំណាពូ ។

ឡាញ់ៈ បាទ!

បូលីៈ មួយអាទិត្យយើងរៀនប៉ុន្មានថ្ងៃកាលហ្នឹង?

ឡាញ់ៈ សម្រាកតែថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ។

បូលីៈ ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្ររៀនធម្មតារហូត ។

ឡាញ់ៈ រៀនរហូត ។ រៀន!

បូលីៈ ចុះថ្ងៃព្រហស្បតិ៍រៀនទេ?

ឡាញ់ៈ រៀន!

បូលីៈ រៀនដែរ?

ឡាញ់ៈ បាទ! រៀន ៗ រៀនយកចិត្តទុកដាក់រៀនមែនទេ កាលហ្នឹង ហើយរៀន គេបង្រៀនបានល្អដែរ ។ កកន្លែងរដ្ឋគេសាលាធំគេរៀនបានល្អណាស់ ហើយចេះទៀត ប្រៀបធៀបថ្នាក់ទី៦ស្មើហ្នឹង យើងនៅ២សព្វថ្ងៃ មិនមែនធម្មតានេះទេ ថាក់ទី៥ ទី៦ ច្រើនរបស់គេ ហើយ ចូលទៅក្នុង គេរៀបចំថាធ្វើបានដល់ក្រសួងស្អី ខាងទូត ខាងអីនោះរៀន ។

បូលីៈ ស្តាយណាស់ ពូអត់បានទៅរៀននៅសាលាធំហ្នឹងគេទេណា៎?

ឡាញ់ៈ អត់បានរៀនទេ ព្រោះខ្ញុំនៅគ្រួសារកងទ័ព វាទៅឆ្ងាយពីសាលាដែរ ។

បូលីៈ សាលាធំមានតែនៅអូរគ្រាវទេ?

ឡាញ់ៈ ៨០អូរគ្រាវ នៅ៨០ ។

បូលីៈ ៨០នៅកន្លែងណា?

ឡាញ់ៈ ៨០នៅកន្លែងធំគេហ្នឹង ។

បូលីៈ ៨០! មិនមែនអូរគ្រាវទេ?

ឡាញ់ៈ មិនមែនទេ! អូរគ្រាវនៅលើនេះទេ ។

បូលីៈ ចឹង?

ឡាញ់ៈ អូរគ្រាវបង្កើតនៅឆ្នាំ ៩០ប៉ុន្មានទេ ។ ៩០ ទៅដឹង!

បូលីៈ អូរគ្រាវ?

ឡាញ់ៈ បាទ!

បូលី:	អូរគ្រាវដូចតាំងពី៨០ដាំងដែរហើយ ។

ឡាញ់:	៨៨ មក៨៩, មក៩០នេះឯង ។ ៩០,៩៣ ចុះមកនេះតែម្តង ។ យ៉ាងច្រើននៅបានតែ ៥ឆ្នាំតា ។

បូលី:	ចឹង?

ឡាញ់:	បាទ! បើ៨០នៅយូរណាស់ ។

បូលី:	អូរគ្រាវ! ចឹងបង្កើតនៅឆ្នាំ៨៥ចឹងណាស់ ។

ឡាញ់:	៨០! បង្កើតនៅឆ្នាំអា៨៦ ។

បូលី:	៨០ហ៎?

ឡាញ់:	បាទ! អាច៨៦ បានបង្កើតឆ្នាំ ១៩៨៦នោះឯងមើលទៅ ព្រោះ៨៤ គេវាយដាច់នៅនេះ ទៅនៅឯនោះឯង ។

បូលី:	បាទ!

ឡាញ់:	៨៦! រហូត បានយើងកាត់អូរគ្រាវ បានយើងប្រមូលចូលអូរគ្រាវទាំងអស់ ។

បូលី:	៨៤ គេមិនវាយដាច់មិនចឹង?

ឡាញ់:	បាទ! ៨៣, ៨៤! គេវាយដាច់ មួយជួរនេះទៅ ទៅនៅជុំគ្នា ទាំង៨០១ ទៅនៅជុំគ្នាដែរតើ! ទៅនៅនោះទាំងអស់ ។

បូលី:	បាទ!

ឡាញ់:	អូរគ្រាវហ្នឹង ។

បូលី:	ហ៎ូ! បានន័យថា មុនគេវាយដាច់អូរគ្រាវ ៨០ ហ្នឹងអត់ទាន់បង្កើតទេ ឬក៏បង្កើតហើយ?

ឡាញ់:	វាយដាច់នេះ យើងទៅនៅឯនោះ ព្រោះខាងវៀតណាម គេយកនេះអស់រលីងហើយ ថាយកទៅនៅលើភ្នំនោះ ។

បូលី:	ខាងឈូករុន ឈូកអីនេះហ្នឹង?

ឡាញ់:	បាទ!

បូលី:	ខាងព្រះប្រឡាយនេះ នោះ?

ឡាញ់:	បាទ!

បូលី:	វាយដាច់អស់ហើយ?

ឡាញ់ៈ វាយដាច់អស់ហើយ បានយើងទៅនៅ៨០ ទៅចាប់៨០រហូតគ្រប់តែកន្លែងទេខាងលើនិយាយចឹង ។

បូលីៈ ដំបូងយើងនៅក្នុងដីខ្មែរ ។

ឡាញ់ៈ នៅដីខ្មែរយើងតើ ។

បូលីៈ មិនមែនមកដល់នេះទេ?

ឡាញ់ៈ អត់ដល់នេះទេ!

បូលីៈ ជើងភ្នំនេះទេ ។

ឡាញ់ៈ ជើងភ្នំនេះប្រហែលជា៧គីឡូ ពីនេះទៅ ។

បូលីៈ ពីនេះទៅ៧គីឡូ?

ឡាញ់ៈ ភូមិនៅនេះទេ ។ ៦១២ណាំ! ៨១១ គេនៅទន្លេល្អៅ ។

បូលីៈ នៅទន្លេល្អៅ ។

ឡាញ់ៈ បាទ! ហើយយើងនៅនេះ ។

បូលីៈ ប៉ុន្តែគ្រាន់តែដឹងថាយើងនៅដីខ្មែរ ។

ឡាញ់ៈ បាទ! នៅក្នុងដីខ្មែររយើង

បូលីៈ បាទ! ដល់តែពេលវៀតណាមវាយទៅ យើងរត់ឡើងលើភ្នំអស់រលីង ។

ឡាញ់ៈ បាទ! នៅដីខ្មែរនេះយើង បង្កើតគ្រួសារកងទ័ពអីនៅដីខ្មែរយើងទាំងអស់ កងទ័ពនៅលើដីខ្មែរនេះ ។ ប៉ុន្តែប្រជាជន គេដោក់នៅឯលើនោះ នៅ៥០ណាំ ។

បូលីៈ បានន័យថា កងទ័ព និងគ្រួសារកងទ័ពនៅឯក្រោម?

ឡាញ់ៈ បាទ! នៅក្រោម ។ ជាពិសេសគ្រូដែលនៅបង្រៀនហ្នឹងពួកគាត់នៅលើនោះ ។

បូលីៈ នៅលើភ្នំនោះ ។ នៅដីថៃ?

ឡាញ់ៈ នៅ៥០ យើងមិនដល់ដីខាងក្នុងពេកទេ នៅប្រហែលពីព្រំប្រទល់នេះទៅហ្នឹងប្រក៥០ហ្នឹងបណ្តោយ ។

បូលីៈ ហ៊ូ! យល់ហើយ ។ ចឹងបានន័យថា ក្នុងកំឡុងពេលដែលវៀតណាម មិនទាន់វាយដាច់ហ្នឹងណាស់ ក្នុងកំឡុងពេលដែលកងទ័ពនិងគ្រួសារកងទ័ពនៅខាងក្រោមហ្នឹង ខាងលើបង្កើតហើយៗ ។

ឡាញ់ៈ បង្កើតនៅសាលានៅលើនោះ បង្កើតនៅ៥០នោះ បង្រៀនសិស្សក្មេងៗឡើង ពួកគ្រូសព្វថ្ងៃនៅអន្លង់វែង គ្រូនាយក គ្រូអីហ្នឹង គ្រូវុនគាត់ហ្នឹងបង្រៀន ។

បូលីៈ គ្រូវុន?

ឡាញ់ៈ បាទ! គ្រូវុន ។

បូលីៈ នៅអន្លង់វែង?

ឡាញ់ៈ បាទ! នៅអន្លង់វែង ។ ប្រធាននាយកគេហ្នឹង!

បូលីៈ ចុះតា នៅ ?

ឡាញ់ៈ តា នៅ គាត់នៅខាងនេះតាហិរញ្ញវត្ថុ ។

បូលីៈ មិនមែនហ៊ុន នៅទេ ខៀវ នៅ ណា ។

ឡាញ់ៈ ខៀវនៅ ។

បូលីៈ ក្អួយតាម៉ុកនោះទៀតណា៎? ថាធ្លាប់ធ្វើគ្រូដែរតាហ្នឹង ។

ឡាញ់ៈ តាហ្នឹងគ្រូៗទៅនៅយើងនៅសាយសុកហ្នឹងឯង ។

បូលីៈ ចឹងសាលាធំ សាយសុកទេ?

ឡាញ់ៈ បាទ! សាលាធំនៅសាយសុក កាលនៅនេះអត់មានទេនៅ៥០ អត់មានទេណា៎ ។ ទល់តែបែកគ្នាទាំងអស់បានទៅនៅ៨០នោះ ប្រមូលផ្តុំគ្នាបង្កើតសាលាធំនៅ៨០នោះ បណ្តោយ ។ ៨០ បុស្សខ្នុរហ្នឹង!

បូលីៈ ៨០ បុស្សខ្នុរទៀត?

ឡាញ់ៈ បាទ! គេហៅ៨០ក៏បាន គេហៅបុស្សខ្នុរក៏បាន ។

បូលីៈ ចឹង?

ឡាញ់ៈ បាទ!

បូលីៈ អីគេបុស្សខ្នុរ?

ឡាញ់ៈ បុស្សខ្នុរហ្នឹងរបស់ថៃ មានដើមខ្នុរ២ ទៅ៣ដើម ហៅបុស្សខ្នុរបណ្តោយ ។

បូលីៈ ចឹងអូរគ្រាវអត់មានសាលាទេ?

ឡាញ់ៈ អត់មានបង្កើតទេ! ក្រោយមកបានគេបង្កើតជំរុំខ្មែរមួយ ខាងបារាំងគេជួយខាងកើតនៅអូរគ្រាវនេះ ។ បានបង្កើតអូរគ្រាវ បង្កើតសាលាបង្កើតអីទៅបាន៨០អីគេឡើងមកនៅអូរគ្រាវហ្នឹងទាំងអស់ ។

បូលីៈ អ៊ូ! ទាល់តែគេបង្កើតអូរគ្រាវ បាន៨០ គេមកនេះទាំងអស់ទៅ ។

ឡាញ់ៈ ដល់ត្រូវគ្នាជាមួយ កិច្ចព្រមព្រៀងនៅប៉ារីសញ្ញៀដើម ត្រូវគ្នាហើយ បានគេបង្កើតគម្រោងមួយ ។ មួយសារហ្នឹង ជុំគ្នាតើ! ជំរកអស់គ្នាទៅ ។ អាហ្នឹងពួក៨០១ ខាងទន្លេ

ល្មោ មកនៅហ្នឹងអូរត្រាវហ្នឹង ហើយខាងយើង ៦១២នេះ នៅ៤០ហ្នឹងក៏ដូចគ្នានៅ អូរត្រាវ ។ ខ្លះគេនៅអូរត្រាវទៅ ខ្លះគេមកនៅយើងនេះវិញ ។ ខាងនេះគេដកអស់ហើយ វៀតណាមគេដកហើយ ។

បូលី: ខាង១០០១នេះ ក៏បែកឆ្នាំ៨៤នេះដែរ ហើយនាំគ្នាមកនៅ១០០៣នេះ ៨៤ហ្នឹងដែរ ។

ឡាញ់: បាទ! ជាប់គ្នា គេនាំគ្នាមកនៅនេះ ។ គេមកនៅភូមិស្អីគេនេះទេមើល ភូមិគ-៧ ។

បូលី: អ៊ូ! ដឹបូងនាំគ្នា មកនៅគ-៧សិន?

ឡាញ់: បាទ! នៅគ-៧ ។

បូលី: អូរត្រាវបាននាំគ្នាមកនៅអូរត្រាវ ។

ឡាញ់: បាទ! បង្កើតអូរត្រាវ បាននាំគ្នាមកនៅអូរត្រាវ ខ្លះគេមកនៅអូរត្រាវខ្លះ ខ្លះមកនៅនេះវិញ ។

បូលី: នៅឯណាវិញ?

ឡាញ់: មកនៅជាំស្វានេះវិញ ។

បូលី: ចឹងជាំស្វា ហើយអូរត្រាវអាចថាបង្កើតនៅប្រហែលជំនាន់ជាមួយគ្នាទេមើលទៅ?

ឡាញ់: អត់ទេ! អូរត្រាវកើតក្រោយនេះទេ ។ ជាំស្វាយើងបង្កើតក្រោយ៤០បន្តិច! តាមកងទ័ពតាមមុខសញ្ញាមួយៗណ៎ ។ ដូចថាកងទ័ពគេ ដូចបងកុសលយើងនេះ គាត់មកនៅយើងជាំស្វានេះ ។ នៅមុខវិញនៅមុខសញ្ញានៅចាប់នេះ ។ ចឹងគាត់គេដកហ្នឹង គ្រួសារកងទ័ព ក៏មកតាមដែរ ។ ហើយខ្លះយើងនេះ៤០ទៅចឹងណ៎ បើតាមអង្គភាពមួយៗនេះ ។

បូលី: ប្រហែលឆ្នាំប៉ុន្មាននៅជាំស្វា ពេលដែល៤០នេះបង្កើត ។

ឡាញ់: ៤០ បើនិយាយឲ្យចំ បើបង្កើតនៅឆ្នាំ១៩៨៦ ។

បូលី: ចឹង១០០៣ បង្កើតតាមពីអង្កាល់?

ឡាញ់: ១០០៣ យើងតាំពី៧៩នេះមក ។

បូលី: កាល៧៩នោះនៅដុំណាទៅ?

ឡាញ់: ព្រោះកងពល!

បូលី: ក្រែង៤០ ជាំស្វាអីហ្នឹងអី ម៉េចគេនៅហៅ១០០៣ហ្នឹងនោះ?

ឡាញ់: ពួកយើងទាំងអស់នោះនៅ១០០៣ ។

បូលី៖ អាហ្នឹងគ្គីចូលគ្នាបានហៅ១០០៣តូ?

ឡាញ់៖ បាទ!

បូលី៖ ចឹងបានន័យថា៨០ ជាំស្វាហ្នឹងក៏បង្កើតទាំងពី៧០៩នេះមកដែរ?

ឡាញ់៖ អត់ទេ! ក្រោយទេ ជាំស្វាក្រោយទេ យើងនៅជាំស្វានេះទៅនៅនឹងចំចម្ការស្វាថៃ គេហៅជាំ ស្វា១បណ្ដោយទៅ។

បូលី៖ អ៊ូ! នៅចម្ការស្វាថៃ?

ឡាញ់៖ បាទ! ដូចនៅនឹងទឹកជប់ គេដាំស្វាពេញអញ្ចឹង យើងរត់ទៅរត់វៀតណាមវ៉ៃនេះដាច់ហ្នឹង យើងរត់នៅជាំស្វា ស្រាប់តែយើងនៅផឹកទឹកជាំស្វាគេហៅជាំស្វារហូតទៅ ដល់ទៅនៅជាំ ស្វា បានប្រហែលមួយអាទិត្យហ្នឹងគេជម្លៀសទៅនៅអីវាលបារាំងធ្លាក់ អូស! វាល បារាំងធ្លាក់អី គេហៅវាលបារាំង១ជួយចែកថ្នាំចែកអី ថ្នាំកូនក្មេងលេបហ្នឹង បាទ! នៅ ហ្នឹងបានប្រហែលជា៣-៤ខែ អ៉េ! មួយឆ្នាំដែរ នៅមួយឆ្នាំ១ក៏កងទ័ពខាងវៀតណាម ខាងរាជរដ្ឋាភិបាលខាងនេះ គេវ៉ៃលុកខាងនេះ យើងរត់ទៅនៅ៤០ទៀតទៅ អញ្ចឹង! យើងរត់បណ្ដាក់១គ្នារហូតទៅ ទៅនៅ៤០មូលនឹង៤០បណ្ដោយ ទម្រាំបានត្រូវគ្នាយើង ត្រូវគ្នាគេបំបែកនៅតាមអគ្គភាពមកនៅ ជាំស្វានេះវិញ។

បូលី៖ បាទ!

ឡាញ់៖ បាទ! នៅជាំស្វា ហើយគេទៅនៅខាងក-៧ ខាង៦១២គេទៅនៅ ៨០១គេទៅក៏ ទៅនៅទៅក-៧ ហើយយើងមកនៅជាំស្វានេះ ហើយនៅខ្លះគេទៅនៅ៤០ ហើយ ដល់អញ្ចឹងទៅ ដល់ឆ្នាំអាច៨៨ ឬ៨៩ ឬ៩០ទេគេនាំគ្នាទៅជំរុំ គេបង្កើតជំរុំហ្នឹង។

បូលី៖ ជំរុំអីគេ?

ឡាញ់៖ ជំរុំអូរត្រាវហ្នឹង។

បូលី៖ បាទ!

ឡាញ់៖ បាទ! គេបង្កើតជំរុំមួយហ្នឹងដើម្បីឲ្យខាងបារាំងគេជួយជំនួយ។ ដល់អញ្ចឹងទៅមានជំនួយ មានអី ទៅគេទៅនៅជំរុំនោះខ្លះ ខ្លះក៏គេមិនទៅគេក៏នៅយើងតាមអគ្គភាពនេះដដែល។

បូលី៖ បន្តនៅតាមក-៧ហ្នឹងទៅ?

ឡាញ់៖ យើងចុះមកនៅនេះវិញ ពួកខ្ញុំចុះមកនៅនេះវិញ ចុះមកនៅដីខ្មែរ អត់ទៅជំរុំអូរត្រាវ ទេ។

បូលី៖ ចុះកាលពី៧៩នៅម្តុំណា?

ឡាញ់: ខ្ញុំ?

បូលី: បាទ!

ឡាញ់: ៧៩ យើងរត់ទៅៗនៅខាងលិច នៅបានប៉ុន្មានរត់បណ្ដាក់គ្នារហូតៗ មកនៅ៨០យើងនៅ រហូត៧៩ដែរ យើងទៅនៅ១០០២ហ្នឹងឯង ។

បូលី: អញ្ចឹងបានន័យថា៨០ ហ្នឹងបង្កើតតាំងពី៧៩-៨០មកហើយ?

ឡាញ់: បាទ! ៧៩នោះ ៨០ហ្នឹង ។

បូលី: ពីដំបូងមក?

ឡាញ់: បាទ! អាហ្នឹងនៅក្នុងតំបន់៨០ គេមានស្រះពីរ មានស្រះទឹកថ្លា ស្រះទឹកល្អក់ ដល់ប្រជាពលរដ្ឋយើងដែលរត់ទៅហ្នឹង ថៃនាំដាក់កន្លែងទឹកស្រះហ្នឹង ស្រះ៨០ហ្នឹងក៏នាំគ្នាដឹកទឹកហ្នឹងទៅ ។

បូលី: ស្រះ៨០ហ្នឹងទៅ?

ឡាញ់: បាទ!

បូលី: ពាក្យថាហ្នឹងបានមកពីណា ៨០ហ្នឹង?

ឡាញ់: ចំណុចលេខព្រំដែន មិនដឹងលេខខាងណា មិនដាថៃ ឬខ្មែរខ្ញុំអត់ដឹងដែរ ។

បូលី: អញ្ចឹងឧទាហរណ៍ថាដាំស្វា វាមានទឹក វាមានដើមស្វា ឈ្មោះដាំស្វាទៅ ដល់វាលបារាំងវាមានបារាំងបែកថ្នាំឲ្យអញ្ចឹងនាំគ្នាហៅវាលបារាំងទៅ ។ បាទ! ចុះចង្កក ហេតុអីគេហៅចង្កក?

ឡាញ់: ចង្កក កាលហ្នឹងខ្ញុំនៅ៨០ គេបង្កើតភូមិចង្កកហ្នឹង ។

បូលី: មានមនុស្សចង្កកនៅហ្នឹងអីបានគេ?

ឡាញ់: អត់មានទេៗ អត់មានមនុស្សចង្កកទេ ដូចមនុស្ស កាលហ្នឹងគេរៀបចំពួកភូមិស្អីគេទេ កាលហ្នឹង ភ្លេចបាត់ហើយ ភូមិហ្នឹងប្រជាជនយើងអ្នករត់ទៅហ្នឹងដែរ គេដាក់យើងនៅភូមិ៨០លើ គេធ្វើនៅភូមិចង្កកហ្នឹង ប៉ុនភូមិចង្កកហ្នឹង មិនដឹងខ្មែរចង្កក ឬក៏វត្តថៃគេហៅចង្កក យើងដឹងតែពីថៃគេហៅចង្កកកន្លែងហ្នឹង យើងអត់ដឹងថាប្រាសាទយ៉ាងម៉េចដែរ ។

បូលី: បាទ! ចុះគ-៧?

ឡាញ់: ខ្ញុំអត់ដឹងទេត្រង់ហ្នឹងនោះ ព្រោះគ-៧ៗមិនដឹងដាថៃគេហៅយ៉ាងម៉េចបានគេដាក់ គ-៧ ឬក៏ខ្មែរផងមិនដឹង ខ្ញុំអត់ដឹងដែរ ។

បូលីៈ ប្រវត្តិវាច្រើនដែលណ៎ពូ?

ឡាញ់ៈ បាទ!

បូលីៈ អូរត្រាវ សង្ស័យតែអូរហ្នឹងមានត្រាវច្រើន?

ឡាញ់ៈ អូរមានត្រាវជូរៗ

បូលីៈ ត្រាវជូរ?

ឡាញ់ៈ បាទ! ត្រាវជូរតូចៗ ស៊ីទៅជូរៗណ៎ៗ

បូលីៈ ហូរត្រាវហ្នឹងហូបទៅជូរតែម្តង?

ឡាញ់ៈ បាទ! ហ្នឹងហើយ រៀងជូរៗស្ងួបន្ទៃ ស្អុីហ្នឹងៗ

បូលីៈ ច្រើនទេពូ?

ឡាញ់ៈ នៅអូរត្រាវហ្នឹង ច្រើនដែលតើ ត្រាវជូរហ្នឹងៗ តាមអូររហូត!

បូលីៈ មានអូរមួយ ហើយមានត្រាវជូរៗ

ឡាញ់ៈ ទិញតែត្រាវជូរហ្នឹង បានអូរត្រាវក្បែរៗគ្នាហ្នឹងៗ

បូលីៈ ត្រាវហ្នឹងរមាស់មាត់ទេ?

ឡាញ់ៈ រមាស់មាត់តា ហូបឆៅៗ

បូលីៈ រមាស់មាត់ដែរណ៎?

ឡាញ់ៈ បាទ!

បូលីៈ គិតទៅប្រវត្តិរបស់គេច្រើនដែរណ៎?

ឡាញ់ៈ បាទ! ជុំរុំអូរត្រាវខ្ញុំបានទៅនៅប្រហែលជា៦ខែដែរតើ! ខ្ញុំមកនៅក្រោមនេះខ្ញុំ ឈឺខ្វាំងពេក ខ្ញុំទៅនៅឯនោះវិញ ខ្ញុំយកគ្រួសារហើយៗ ដល់ទៅនៅនោះដូចទើបតែចេះរកស៊ីអីគេ ខ្ញុំមកនៅដីខ្មែរវិញៗ នៅដីខ្មែរ ខ្ញុំនៅកងទ័ពវិញទៅ ខ្ញុំនិយាយឲ្យចំទៅគ្រួសារកងទ័ព ខ្ញុំនិយាយនៅញូងទ័ពរហូតហ្នឹង ប៉ុន្តែមិនដែលទៅវាយហ្នឹងគេទេៗ មិនដែលទៅច្បាំងហ្នឹងគេ ទេៗ

បូលីៈ អត់មានចូលទៅធ្វើការនៅឯក្នុងទេ?

ឡាញ់ៈ អត់ទេ! អត់ដែរទៅទេៗ បានតែមួយត្រឹមដឹកជញ្ជូន គ្រាប់ហើយហ្នឹង អង្ករហើយចម្រូង អីដើរតាមនេះៗឯងឲ្យទៅវាយ មិនដែលបានទៅវាយទេខ្ញុំៗ

បូលីៈ ចឹងដូចថាយើងចូឡើងភ្នំអីដូច ថាគេឲ្យ ដើរសេរីដែរ?

ឡាញ់ៈ ដើរតើ! មានអីៗ

បូលីៈ គេអត់ហាមឃាត់ ហាមអី?

ឡាញ់ៈ អត់មានហាមឃាត់អី ។

បូលីៈ នៅម្តុំណា គឺនៅម្តុំហ្នឹងហើយ ។

ឡាញ់ៈ អត់ទេ! ឃើញទៅមកៗ គេមកលេងគ្រួសារគេ គ្រួសារគេនៅមុខនេះ នៅលើចេះ ទៅលេងគ្រួសារគេ ។ ល្ងាចឡើងទៅវិញទៅ!

បូលីៈ ហើយផ្លូវដើរយ៉ាងម៉េចដែរផ្លូវដើរ ។

ឡាញ់ៈ ផ្លូវដើរយើង! កាលហ្នឹងគេធ្វើ គេមានអាត្រាក់គេរុញដែរតើ ។ អត្រាក់រុញជាផ្លូវយើង មិនចាក់គ្រួសទេ ។

បូលីៈ ពូចុះតាមច្រកណា៎?

ឡាញ់ៈ ចុះតាមឈូករុនយើងនេះ ។ គេធ្វើផ្លូវរហូតដល់តែយើងមកនៅឆ្នាំ៩៣ ជំនាន់អ៊ុនតាក់ នេះហើយ យើងនៅនេះបានបង្កើតថៃ គេដឹកឈើ គេដឹកអីហ្នឹង គេរុញផ្លូវរុញឲ្យចាក់ គ្រួសៗ ខ្វះហ្នឹង ។ មានឡាន មានអី!

បូលីៈ ថៃដឹកឈើ តាមឈូករុនហ្នឹង?

ឡាញ់ៈ បាទ! មានគេធ្វើផ្លូវឲ្យច្រកដឹក ឈើហ្នឹងទៅ ។

បូលីៈ ឡើងលើភ្នំនោះរួចដែរ ។

ឡាញ់ៈ គេធ្វើឡើងទាប! ទាបចុះដាងអន្លង់វែងយើងទៀតនោះ ។

បូលីៈ ច្រកឈូករុននោះ?

ឡាញ់ៈ បាទ!

បូលីៈ ចឹងបានន័យថាច្រកនេះ បើកមុនអន្លង់វែង បើកកាលពីមុន ថៃដឹកឈើនោះ វាយបុក នោះ ។

ឡាញ់ៈ ចឹងតាម៉ុក ដឹកឈើតាមច្រកនោះទេចឹង?

បូលីៈ បាទ! តាមច្រកហ្នឹងឯង ។

ឡាញ់ៈ មិនមែនតាមច្រកដាំទេណា៎?

បូលីៈ អត់ទេ!

ឡាញ់ៈ ដាំហ្នឹងបើដឹកឈើនេះ ឈើប្រណិត អាឈើយើងអាររួចណា៎ ។ អាឈើទាំងមូលៗ តាមនេះហើយ ។

បូលីៈ បើឈើអាររួច ចូលតាមច្រកដាំ ។

ឡាញ់ៈ បាទ! អាហ្នឹងប្រកដាំ ព្រោះខ្ញុំនៅនេះ បើគេមានរោងចក្រគេមួយធំណាំ រោងចក្រឈើ គេនៅតែដឹកចេញចឹងទៅនោះបណ្ដោយ ។ នេះគ្មាននរណាដឹកឈើធំទេ ។ ឡានអាត្រាក់ គេគគ្រឹកគគ្រេង ច្រើនទេពូដឹក ហ៊ូច្រើនណាស់មួយយប់ ទៅពីរយប់ ។ មួយថ្ងៃរាប់ពាន់ ដើម ។

បូលីៈ ដឹកមួយយប់ទល់ភ្លឺតែម្ដង?

ឡាញ់ៈ ទាំងយប់ទាំងថ្ងៃ និយាយឲ្យចំទៅ ។ អាដឹកទាន់ៗក៏ទាន់ទៅ ហើយអាណាដឹកមិនទាន់ក៏ ភ្លើងឆេះអស់មិនចេះតិចពាន់ដើមទេ ។ អាគដឹកនៅនេះ!

បូលីៈ ម៉េចចឹង?

ឡាញ់ៈ ដល់វារុញហើយ! មិនរុញដាក់ៗ មិនទាន់គាស់គីបដង មិនស្មៅវាដុះ ស្មៅដុះដល់ខែ៥ ចេះ មិនមិនងាប់អាស្មៅភ្លើងឆេះ ខូចអស់ឡើងរាប់ពាន់ដើមនោះ ។

បូលីៈ ស្ដាយណាស់ណាំ!

ឡាញ់ៈ រាប់ពាន់ រាប់ម៉ឺននោះមិនស្រួល!

បូលីៈ ឈើធំណាស់ពូ?

ឡាញ់ៈ លែងសុទ្ធតែខ្នាតៗនេះ ។ ធំណាស់ៗ!

បូលីៈ សុទ្ធតែនាងនួន សុទ្ធអីនុំ ។

ឡាញ់ៈ សុទ្ធតែឈើទាល ហើយហ្នឹងគគីទេដែលដឹក ។

បូលីៈ ចឹងហាំ?

ឡាញ់ៈ បាទ!

បូលីៈ នាងនួនប៉េងអីអត់ដឹងទេ?

ឡាញ់ៈ អត់ទេ! ម៉េចចឹង អត់មានហាងឆេង ។ មានតែឈើទាល គគីទេ ។

បូលីៈ ថៃវាអត់ចូលចិត្តបេង ហ្នឹងនាងនួន?

ឡាញ់ៈ ក្រញ៉ូងអី?

បូលីៈ អត់ ។

ឡាញ់ៈ ទៅចឹងវិញទៅ ។ វាដឹកទៅធ្វើតែផ្ទះម្ដែង ។ ឈើអស់ហ្នឹង ឈើធ្វើផ្ទះតែម្ដង ។

បូលីៈ វាមាំណាំពូណាំ?

ឡាញ់ៈ បាទ! សម្រាប់ឈើធ្វើផ្ទះ បើនិយាយរឿង បេង ក្រញ៉ូង នាងនួនអីសម្រាប់គ្រែ តុ ទូ គេមិនហានទេ គេមិនហានដឹក ។

បូលី៖	ហើយចុះ ពេលដែលគេផ្ដាច់ខ្លួន ពូទៅណាហ្នឹងគេដែរ?

ឡាញ់៖	ផ្ដាច់ខ្លួន ខ្ញុំនៅជាមួយទាំងអស់គ្នាដែរ ។

បូលី៖	អត់មានផ្ដាច់ខ្លួនរស់តាមគេ?

ឡាញ់៖	អត់ទេ! គេមកផ្ដាច់នៅហ្នឹងយើង ។ អូរស្វាយនៅឯកើត នៅអីលិច ។ ពេលតាជុំ ពេលតាអុីង លាង អីរត់ណា៎?

បូលី៖	បាទ! ចាំមើល តាជុំ គាត់រត់ គាត់រត់ទៅមួយសារចេះ ហើយខ្ញុំនៅក្រោយចេះ ក្រោយមក ខ្ញុំនៅគ្រប់គ្រងខាងអើយ! គ្រួសារ០៥នោះ ព្រោះអ្នកដែលមានទោស មិនតាម៉ុកគាត់មិនរត់ប្រហារ០៥នោះ ។ កាលហ្នឹងខ្ញុំនៅគ្រប់គ្រងមីង១ នោះឯងមកដាក់ទំនប់ដាច់នេះ ខ្ញុំមកគ្រប់គ្រងនៅហ្នឹងដដែរជាមួយមេឃុំយើងនេះ សព្វថ្ងៃនោះ ។ មេឃុំសព្វថ្ងៃជាមួយខ្ញុំហ្នឹង ដឹកគ្រប់គ្រងគាត់ហ្នឹងឯង ។ គ្រប់គ្រងមីង១!

ឡាញ់៖	តាម៉ុក ឲ្យមកគ្រប់គ្រង?

បូលី៖	បាទ!

ឡាញ់៖	ដល់តែ គេវាយពួកតាលាង មកវាយយកនេះវិញណា យើងនាំគ្នារត់ទៅនៅឯ៤០នោះឯងក្រោយនោះ ។ ៤០អី! អូរស្វាយនោះ ។ ដល់តែយើងនៅនោះប្រហែលបានជាប៉ុន្មានថ្ងៃ ហើយបានគេនិយាយត្រូវគ្នា គាត់ដាច់ខ្លួនទាំងអស់គ្នាចូលទាំងអស់កគ្នានៅអូរស្វាយ ។

បូលី៖	កាលហ្នឹងចរចារគ្នាយ៉ាងម៉េច?

ឡាញ់៖	ចរចាតារយៈ តារយៈអើយកងទ័ពគេត្រូវគ្នានោះ តាមម្ដាយគេនោះ ។ ដូចតា លាងតាអីនោះ ត្រូវគ្នាទៅ គេចរចាគ្នាទៅវិញទៅមក ។

បូលី៖	ប៉ុនពូមានគ្នាប៉ុន្មាននាក់ដែលទទួលបន្ទុកនៅក្នុងការមើលការខុសត្រូវលើគ្រួសារតា០៥ ហើយហ្នឹងប្រជាជន ដែលប្ដីរត់ចោលដូរហ្នឹង ។ គ្នាពូប៉ុន្មាននាក់ទាំងអស់?

ឡាញ់៖	ខ្ញុំមានប៉ុន្មាននាក់ដែរ មានឃុំ មានខ្ញុំ មាននៅក្នុងឃុំមួយតាសារូនោះបាទ! យកមកគ្រប់គ្រងមីងនោះ ហើយតាម៉ុកឲ្យតាអីដាច់ជើងនោះ អាហ្នឹងមួយ! តាមីធំនោះ ខ្ញុំគ្រាន់តែមកដល់ ខ្ញុំគ្រប់គ្រង គ្រាន់តែឈរការមើលទេ ប៉ុន្តែប្រជាជនខ្ញុំមាន មកនៅជាមួយខ្ញុំនោះ មកនៅទំនប់ដាច់ហ្នឹង មានប៉ុន្មានប្រហែលជា២០គ្រួសារដែរភ្ជាប់មកជាមួយពួកខ្ញុំហ្នឹងនៅហ្នឹង ហើយជាមួយមីង១ ខាងដែលខាងពួក០៥ហ្នឹង វាចូលហ្នឹងដែរហើយគាត់មកនៅម្ដុំ ពួកខ្ញុំហ្នឹងនៅម្ដុំទៅ ។

បូលីៈ ពីណាគាមេឃុំ ឬក៏គាជំទប់ទីមួយ?

ឡាញ់ៈ ប៉ុនឃុំសព្វថ្ងៃ គាវ៉ុន ។

បូលីៈ ចុះមេឃុំសព្វថ្ងៃនៅជាមួយពូដែរ?

ឡាញ់ៈ បាទ! ខ្ញុំនៅជាមួយគាត់ហ្នឹង

បូលីៈ មើលខុសត្រូវគាកូនក្រុមគ្រួសារ០៥ហ្នឹងហ៎?

ឡាញ់ៈ បាទ! នៅហ្នឹង ។

បូលីៈ ពេលហ្នឹង តាម៉ុក បញ្ជោមកចឹងតែម្តង?

ឡាញ់ៈ បាទ! គេចាត់តាំងមកឲ្យយើងនៅហ្នឹងតែម្តង ។

បូលីៈ ព្រោះប្តីគេរត់អស់ហើយណ៎?

ឡាញ់ៈ ប្តីរត់អស់ហើយ ។ ទេ! គ្រប់គ្រងនែក ក្រុមគ្រួសារ០៥ទេ។ ០៥ ហើយហ្នឹងតាយន គ្រួសារតាយន គ្រួសារពីណាខ្លះទៅ តាសែន ។

បូលីៈ ដែលទៅសម្លាប់ចោលហ្នឹងណ៎?

ឡាញ់ៈ មិនមែនសម្លាប់ចោលទេ គេចាប់ទៅដាក់គុកនៅឯណាឯណីទេ ខ្ញុំមិនដឹងដែរ រឿងហ្នឹង នោះ យើងអ្នកក្រោម យើងអ្នកនៅដឹងគេអ្នកធ្វើការខាងក្នុងអីលើ ។

បូលីៈ ចុះគាជំទប់ទី១នេះ?

ឡាញ់ៈ គាត់កងទ័ព ។

បូលីៈ កងទ័ព៦១៧ដែរ?

ឡាញ់ៈ បាទ!

បូលីៈ គាត់រត់ ឬក៏គាត់នៅខាងតាម៉ុក?

ឡាញ់ៈ នៅទាំងអស់គ្នា និយាយឲ្យចំទៅ ទាំងអស់តែគ្នាទេ គាត់នៅនេះ គេដកគាត់មកធ្វើការនៅ គេគ្រប់គ្រងនេះ ។

បូលីៈ គាត់គ្រប់គ្រងនៅហ្នឹងដែរ?

ឡាញ់ៈ គ្រប់គ្រងនៅហ្នឹងទៅ ។ ហើយខាងតាម៉ុកនោះគាត់អត់ឲ្យបងអីមួយទេ គាត់កំបុតជើង នោះភ្លេចឈ្មោះបាត់ហើយ ក៏មកពីតាម៉ុកនោះមក ហើយខាង៦១៧ ជំនាន់នេះមក ហើយបើមកនៅឃុំមើលខ្ញុំ និងតាសារូ បាទ! គ្រប់គ្រង ប៉ុន្តែមិនធ្វើគេ ដាំបាយហូប ធម្មតា ធ្វើស្រែ ធ្វើអីធម្មតា ។

បូលីៈ យើងអត់មានទៅធ្វើបាបធ្វើអី?

ឡាញ់ៈ អត់មានធ្វើអីគេទេ!

បូលីៈ ហើយដល់ពេលខាងនោះគេវាយចូលមក គេវាយនៅអូរស្វាយ ។

ឡាញ់ៈ យើងទៅអូរស្វាយទាំងអស់គ្នា ។ ហើយគេរត់ទៅខាង អូរស្វាយទេ ប៉ុន្តែដេកក្រោមនោះទៅ ភូមិគេចាស់នោះណាស់ ហើយខ្ញុំទៅភូមិចាស់ទៅ ។

បូលីៈ ហើយយើងចរចាគ្នា យ៉ាងម៉េចបានៗខាងតាដុំ តាអីបានប្រពន្ធកូនទៅវិញ?

ឡាញ់ៈ មកនេះវិញ ទាំងអស់គ្នាហ្នឹង កូនមានទៅណា នៅហ្នឹងទាំងអស់គ្នាហ្នឹង ។

បូលីៈ មុនហ្នឹងមក វាមិននិយាយគ្នាសិនអី មិនមែនចេះតែមកៗណា?

ឡាញ់ៈ មកគេចេះ! ត្រូវគ្នាហើយកងទ័ព គ្រប់ខាងនេះខាង មកចូលជុំគ្នាអស់វិញហើយណា ទាំងកងទ័ព គាត់មក!មកវិញ ចូលក្រុមគ្រួសារសិនបាទ ។

បូលីៈ មាន(ស្តាប់ពុំបាន)ដាក់គ្នាសិនទេ?

ឡាញ់ៈ អត់ទេ! អត់មានវាយ គ្នាខ្លាំងទេ វាយគ្នាបានតែបន្តិច ម្តុំនេះឯង ម្តុំយើងទីនេះវាយ ។

បូលីៈ ពេលហ្នឹងតាម៉ុក គាត់ឡើងលើភ្នំទៅ?

ឡាញ់ៈ តាម៉ុក គាត់ឡើងលើភ្នំទៅៗ ។

បូលីៈ ហើយពូអត់ឡើងទៅភ្នំហ្នឹងគេទេ?

ឡាញ់ៈ អត់ទេ!

បូលីៈ ពូមកខាងទំនប់ដាច់វិញ?

ឡាញ់ៈ បាទ! ត្រឹមអូរស្វាយមកផ្តាច់ខ្លួនមកមុនបណ្តោយពួកយើងខាងអន្លង់វែង គេរត់ទៅលើភ្នំជាមួយតាម៉ុក មួយទៀត ។

បូលីៈ អ្នកផ្តាច់ខ្លួន គេទៅតាមអូរបែតាប់?

ឡាញ់ៈ មួយបែកគេទៅ អូរបែតាប់ មួយបែកគេទៅឡើងទៅលើ ។

បូលីៈ ចុះក្រុមពូអត់ឡើងទៅលើនឹងគេទេ?

ឡាញ់ៈ អត់ឡើងគេទេ នៅទំនប់ដាច់ហ្នឹងបណ្តោយ ។

បូលីៈ រត់មកក្រោយវិញ?

ឡាញ់ៈ បាទ! ដល់ត្រូវគ្នាផ្តាច់ខ្លួនមក ពួកយើងមិនរត់នៅនេះវិញបណ្តោយ ។ យើងរត់មកនៅទំនប់ដាច់នេះវិញ យើងអត់ទុកចោលភូមិអូរស្វាយក្រោយនោះ ហើយយើងមកនៅទំនប់ដាច់ ។ មកនៅទំនប់ដាច់ហើយបាន ទ័ពខាងនេះគ្រប់ភាគីទាំងអស់មក បានគេដឹកអង្ករ

ដឹកអីយកមកពីខាងយន្តហោះ តាមអីមក(ស្តាប់ពុំបាន) ចែកអង្ករចែកអី! ស្មៀកពាក់ធម្មតា ។

បូលី៖ តាទាបាញ់មកផ្ទាល់តែម្តង?

ឡាញ់៖ បាទ! មក ។

បូលី៖ ពេលនោះចាប់មកភ្នំពេញវិញនៅ?

ឡាញ់៖ នៅ ។

បូលី៖ តាទាបាញ់ម៉េចហានចូលមកណ៎?

ឡាញ់៖ នៅទេ! ព្រោះតាម៉ុកគ្នាប៉ុន្មាននាក់ បងកុសលអីនេះ នៅលើភ្នំដែរ ។

បូលី៖ បងកុសលនៅលើភ្នំដែរ?

ឡាញ់៖ នៅភ្នំដែរ ទម្រាំយើងបានត្រូវគ្នាខ្មែរទាក់ទងគ្នា បានឲ្យចុះមកវិញទាំងអស់ ខុសគ្នា ។ ក្រោយមកបានចុះមកវិញទាំងអស់គ្នា ។

បូលី៖ ចឹងមុនអាយើងធ្វើអាពិធីសមាហរណកម្ម តា ទា បាញ់ចូលមកដែរ?

ឡាញ់៖ មកតើ! គាត់មក ។

បូលី៖ គាត់មក គាត់និយាយថាម៉េចខ្លះ?

ឡាញ់៖ កាលហ្នឹង គេឲ្យយើងទៅបៀតគាត់ ។

បូលី៖ តែគាត់មាននិយាយតាមេក្រូទេ?

ឡាញ់៖ អត់ទេ! គាត់គ្រាន់តែ បញ្ចោរកូនចៅគាត់ ។ មកច្រើនណាស់មេៗធំកាលហ្នឹង ។ មកអបអរ កាលហ្នឹងគាត់មកជួបមេៗធំ ។

បូលី៖ គាត់ឈ្មោះអី?

ឡាញ់៖ អ្នកស្លាប់ថ្ងៃមុននោះ ។

បូលី៖ ចឹងគាត់កើតអី?

ឡាញ់៖ ផ្ទុះមីន!

បូលី៖ ផ្ទុះមីន!

ឡាញ់៖ ផ្ទុះគ្រាប់មិនទាន់ផ្ទុះ ។

បូលី៖ នៅឯណាពូ?

ឡាញ់៖ នៅភូមិខ្ញុំ ។ សុទ្ធតែកងទ័ព!

បូលី៖ សុទ្ធតែកងទ័ពណ៎?

ឡាញ់៖ បាទ!

បូលី៖ ខ្ញុំដូចជាមានតែប៉ុណ្ណឹងទេណ៎ពូណ៎?

ឡាញ់៖ បាទ!

បូលី៖ អគុណពូហើយ ដែលបានជជែកគ្នាលេងណ៎ា បានខ្ញុំបានដឹងរឿងយ៉ាងច្រើនពីពូ ពីប្រវត្តិហ្នឹងណាពូណ៎ា ។

ឡាញ់៖ បាទ! ខ្ញុំដឹងត្រឹមតែខ្ញុំដើរត្រឹមហ្នឹង ។

បូលី៖ អគុណហើយពូណ៎ា ។

«ចប់»